ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គម

# BENEFITS OF USING HEALTH CARE SERVICES AND OCCUPATIONAL RISK OF THE NATIONAL SOCIAL SECURITY FUND

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គម

# BENEFITS OF USING HEALTH CARE SERVICES AND OCCUPATIONAL RISK OF THE NATIONAL SOCIAL SECURITY FUND

គ្រូណែនាំ៖ ហុង លក្ខិណា

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

# គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២
# ប្រធានបទ៖ អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គម

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

ហុង លក្ខិណា

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយកមជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករងមជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យនៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ដែលពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេស ក្រុមយើងខ្ញុំបានយល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញដែលមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការគណនេយ្យដូចគ្នា។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិត កាន់តែមានគុណភាពខ្ពស់សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារគណនេយ្យ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីមួយ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យបានយល់ច្បាស់ពីការអនុវត្តការងារគណនេយ្យ ពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតប ឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី**"អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គម"** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គម។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណាមួយនេះឡើង នឹងបានចូលរួមចំណែកមួយក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃទៀតដែលមានគោលបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



**ចាប លក្ខិណា**

ID: B22/2361



**ស៊ុន នាត**

ID: B22/2270



**ម៉ាត់ រ៉ូស៊ីកា**

ID: B22/1786



**ញ៉ឹប ដាលីន**

ID: B22/2395



**ទ៉ាត មាលា**

ID: B22/2362

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញគណនេយ្យ

**សូមសម្តែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសម្តែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់ខ្ញុំបាទ នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្តាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសម្តែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះអ្នកគ្រូ **ហុង លក្ខិណា** ជាគ្រូណែនាំ ដែលបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតដល់ធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមយើងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២៖

សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទស្តីអំពី "អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គម" នេះគឺពិតជាស្នាដៃមួយរបស់ក្រុមខ្ញុំបាទ នាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលដែលទាក់ទងទៅនឹងការស្រាវជ្រាវ ដែលបានលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃពុធ ៨កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**

ចាប លក្ខិណា

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

របបសន្តិសុខសង្គមបានចាប់កំណើតនៅព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ ១៩៤០ យោងតាមព្រះរាជក្រឹត្យលេខ៣០៦ន.ស។ តែគួរឱ្យសោកស្តាយកំឡុងពេលរបបប្រល័យពូជសាសន៍ឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ របស់សន្តិសុខសង្គមនេះត្រូវបានបំផ្លាញចោលទាំងស្រុង ។ ហើយបន្ទាប់ពីការបោះឆ្នោតឆ្នាំ ១៩៩៣នាយកដ្ឋានសន្តិសុខសង្គមត្រូវបានបង្កើតឡើងវិញ។ របបបេឡាជាតិសន្តិសុខសង្គម គឺជាយន្តការមួយដែលមានសារៈសំខាន់ដែលត្រូវបានរៀបចំ និងចែតចែងឡើងដោយរដ្ឋ ដើម្បីធានានូវសុខុមាលភាពផ្នែកសុខភាព និងហានិភ័យការងារ និងជីវភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងធានាអត្ថិភាពការងារជានិរន្តរក្នុងគោលដៅការពារផលប្រយោជន៍ផ្នែកសន្តិសុខសង្គមដល់សមាជិករបស់ខ្លួន។ ហើយគ្រប់សមាជិកដែលបានចុះឈ្មោះនៅបេឡាជាតិសន្តិសុខសង្គម ឬបុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ស្តីពីការងារមានសិទ្ធទទួលបានសេវាប្រើប្រាស់នៅបេឡាជាតិសន្តិសុខសង្គមទាំងអស់។

របបបេឡាជាតិសន្តិសុខសង្គម បង្កើតឡើងដើម្បីជួយដល់ប្រជាពលរដ្ឋ កម្មករនិយោជិត ឬបុគ្គលស្វ័យនិយោជន៍ សម្រាប់ប្រើប្រាស់ផ្នែកសេវាថែទាំសុខភាពនូវពេលដែលជួបហានិភ័យសង្គមនានា ឬជួបប្រទះនូវកំឡុងពេលបំពេញការងារ។ បេឡាជាតិសន្តិសុខសង្គមបានចូលរួមជាច្រើនក្នុងការជួយលើកកម្ពស់សុខុមាលភាពសាធារណៈ ធានាឱ្យមានសមធម៌ និងសាមគ្គីធម៌ ការអភិវឌ្ឍន៍គោលយោបាយសង្គម និងសេដ្ឋកិច្ចការអភិវឌ្ឍន៍ទៅលើវិស័យសុខភិបាលកាន់តែរីកចម្រើន កាត់បន្ថយភាពក្រីក្រដល់ប្រជាពលរដ្ឋ ជួយសម្របសម្រួលដល់ជីវរស់នៅរបស់ប្រជាពលរដ្ឋ ។ ហើយបច្ចុប្បន្ន បេឡាជាតិសន្តសុខសង្គមបានធ្វើការសហការជាមួយមន្ទីពេទ្យជាច្រើនគ្រប់ខេត្ត ក្រុង ដើម្បីផ្តល់ភាពងាយស្រួលដល់សមាជិកបេឡាជាតិសន្តសុខសង្គមក្នុងការប្រើប្រាស់មន្ទីពេទ្យតាមបណ្តាលខេត្តនានា។ ម៉្យាងទៀត ការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គមមិនត្រឹមតែជួយកាត់បន្ថយហានិភ័យសុខភាពសម្រាប់និយោជិតប៉ុណ្ណោះទេថែមទាំងរួមចំណែកយ៉ាងសំខាន់ក្នុងការកសាងសង្គមមានស្ថេរភាព និងយុត្តិធម៌។

សរុបរួមមក បេឡាជាតិសន្តិសុខសង្គម គឺបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនជូនប្រជាពលរដ្ឋ ការអភិវឌ្ឍន៍ទៅលើវិស័យសុខាភិបាល និងការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចផងដែរ។ បេឡាជាតិសន្តិសុខសង្គមជាផ្នែកមួយនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការធានាសុខភាព និងស្ថេរភាពសង្គម។ សេវាបេឡាជាតិសន្តិសុខសង្គមមិនត្រឹមតែជួយរក្សាសុខភាពបុគ្គលប៉ុណ្ណោះទេ ថែមទាំងជួយពង្រឹងសង្គម និងសេដ្ឋកិច្ចជាតិឱ្យមាននិរន្តរភាព ហើយមានតួនាទីសំខាន់ក្នុងការគាំពារសុខភាព ស្ថេរភាពហិរញ្ញវត្ថុ និងការអភិវឌ្ឍន៍សង្គមជាតិតាមរយៈសេវាធានារ៉ាប់រងដ៏ចម្រុះ។

# មាតិកា

ទំព័រ

អារម្ភកថា ........ i

រចនាសម្ព័ន្ធក្រុម ........ ii

សេចក្តីថ្លែងអំណរគុណ ........ iii

អំណះអំណាង ........ iv

សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v

មាតិកា ........ vi

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១

១. តើលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គមមានអ្វីខ្លះ?

២. តើការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គមបានផ្តល់អត្ថប្រយោជន៍អ្វីខ្លះ?

១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២

១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២

១.៤.១ ទំហំដែនកំណត់ ........ ២

១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ........ ២

១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣

១.៥.១ បកស្រាយតាមលំនាំសំណួរទី១ ........ ៣

១.៥.២ បកស្រាយតាមលំនាំសំណួរទី២ ........ ៣

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៥

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៦

## ជំពូកទី២
## អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គម

២.១ លក្ខណៈទូទៅនៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងារ ........ ៧

២.១.១ និយមន័យថែទាំសុខភាព ........ ៧

២.១.២ ប្រវត្តិថែទាំសុខភាព ........ ៧

២.១.៣ ទ្រឹស្តីថែទាំសុខភាព ........................................................................ ៨
២.២ លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងារ ........... ៩
២.២.១ និយមន័យហានិភ័យការងារ ........................................................................ ៩
២.២.២ ប្រវត្តិហានិភ័យការងារ ........................................................................ ១០
២.២.៣ ទ្រឹស្តីហានិភ័យការងារ ........................................................................ ១១
២.៣ អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គម
២.៣.១ និយមន័យអត្ថប្រយោជន៍ ........................................................................ ១២
២.៣.២ ទ្រឹស្តីអត្ថប្រយោជន៍ ........................................................................ ១២

## ជំពូកទី៣
## អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់ បេឡាជាតិសន្តិសុខសង្គម

៣.១ ស្ថានភាពទូទៅរបស់បេឡាជាតិសន្តិសុខសង្គម ........................................................ ១៣
៣.១.១ ប្រវត្តិរបស់បេឡាជាតិសន្តិសុខសង្គម ........................................................ ១៣
៣.១.២ បេសកកម្ម ទស្សនវិស័យ និងគោលដៅរបស់បេឡាជាតិសន្តិសុខសង្គម ................ ១៤
៣.១.៣ រចនាសម្ព័ន្ធរបស់បេឡាជាតិសន្តិសុខសង្គម ........................................................ ១៦
៣.២ លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គម ........................................................ ១៧
៣.២.១ លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងារ១៧
ក. ការចុះបញ្ជីរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងហានិភ័យការងារ........... ១៧
ខ. លក្ខខណ្ឌនៃការទទួលបានសេវាប្រើប្រាស់នៅបេឡាជាតិសន្តិសុខសង្គម................ ១៨
៣.២.២ ការបង់ភាគទានផ្នែកថែទាំសុខភាព និងហានិភ័យការងារ ................................ ១៩
៣.៣ អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គម
៣.៣.១ អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាថែទាំសុខភាព ........................................ ២០
ក. សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ........................................................ ២០
ខ. ប្រាក់បំណាច់ប្រចាំថ្ងៃព្យាបាលជំងឺ........................................................ ២២
គ. ប្រាក់បំណាច់មាតុភាព ........................................................................ ២២
ឃ. វិភាជន៍បូជាសព........................................................................ ២៣
ង. ដៃគូរសហការក្រសួងសុខាភិបាល ........................................................ ២៣
៣.៣.២ អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាធានារ៉ាប់រងហានិភ័យការងារ.................................. ២៤
ក. ការផ្តល់សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ........................................................ ២៤
ខ.ប្រាក់បំណាច់សម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ......................... ២៤
គ. ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ .............................. ២៤

ឃ. វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ............................... ២៥
ង. វិភាជន៍បូជាសព និងធនលាភឧត្តរជីវី ........................................................ ២៥
ច. សេវាស្តារនីតិសម្បទា ............................................................................ ២៨

**ជំពូកទី៤: ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ**

៤.១ ការវិភាគលើចំណុចខ្លាំង........................................................................ ២៩
៤.២ ការវិភាគលើចំណុចខ្សោយ ...................................................................... ៣០

**ជំពូកទី៥: សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**

៥.១ សេចក្តីសន្និដ្ឋាន ................................................................................. ៣១
៥.២ ការផ្តល់អនុសាសន៍ .............................................................................. ៣១

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា ជាប្រទេសដែលកំពុងអភិវឌ្ឍទៅលើគ្រប់វិស័យរួមមាន វិស័យសុខាភិបាល វិស័យអប់រំ វិស័យទេសចរណ៍ វិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យគមនាគមន៍ និងវិស័យជាច្រើនទៀត។ល។ ក្នុងនោះយើងសង្កេតឃើញថា វិស័យសុខាភិបាលនៅក្នុងប្រទេសកម្ពុជាកំពុងមានការអភិវឌ្ឍ និងការរីកចម្រើនលូតលាស់យ៉ាងល្អទៅលើផ្នែកសេវាថែទាំសុខភាព ដែលមានការបង្ហាញពីការយកចិត្តទុកដាក់ ទើបរាជរដ្ឋាភិបាលរបស់ប្រទេសកម្ពុជាបានដាក់ការស្នើរសុំព្រះរាជក្រឹត្យបង្កើតរបបបេឡាជាតិសន្តិសុខសង្គមជូនដល់ប្រជាពលរដ្ឋសម្រាប់ប្រើប្រាស់ផ្នែកសេវាថែទាំសុខភាពនូវពេលដែលប្រជាជនជួបហានិភ័យសង្គមនានាដែលជួបប្រទះនូវកំឡុងពេលបំពេញការងារ។ របបបេឡាជាតិសន្តិសុខសង្គមបានជួយសម្របសម្រួលដល់ជីវភាពរស់នៅរបស់ប្រជាជនឱ្យជៀសផុតពីភាពក្រីក្រ និងជួយសម្របសម្រួលនូវពេលដែលជួបឧបទ្ទវហេតុនានាដូចជា ផ្នែកថែទាំសុខភាព និងហានិភ័យការងារ។

ការអនុវត្តបេឡាជាតិសន្តិសុខសង្គមផ្នែកសេវាថែទាំសុខភាព និងហានិភ័យការងារត្រូវបានអនុវត្ត និងអនុលោមតាមច្បាប់ស្តីពីការងាររបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងអនុក្រឹត្យពីការបង្កើតបេឡាជាតិសន្តិសុខសង្គមដោយស្របតាមយុទ្ធសាស្ត្របញ្ចកោណ យុទ្ធសាស្ត្រអភិវឌ្ឍជាតិ  យុទ្ធសាស្ត្រគាំពារសង្គមសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ យុទ្ធសាស្ត្រអភិវឌ្ឍហិរញ្ញវត្ថុ យុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ បេឡាជាតិសន្តិសុខសង្គមបានផ្តល់ប្រយោជន៍ជាច្រើនទៅកាន់ប្រជាជនទៅលើផ្នែកសេវាថែទាំសុខភាពគ្រប់ទីកន្លែងមិនថានៅតាមទីក្រុង ឬតាមជនបទឡើយ ពោលគឺមានការផ្តល់ជូននូវសេវាថែទាំសុខភាពបានយ៉ាងល្អនូវពេលដែលប្រជាជនជួបបញ្ហាណាមួយដែលទាក់ទងនឹងផ្នែកសុខភាព និងហានិភ័យការងារជាដើម។ បេឡាជាតិសន្តិសុខសង្គមក៏បានពង្រីកការចុះកិច្ចព្រមព្រៀងជាមួយមន្ទីរពេទ្យសាធារណៈ និងឯកជនមួយចំនួន និងបានដាក់ភ្នាក់ងារឱ្យនៅប្រចាំការនៅតាមមន្ទីរពេទ្យសម្រាប់សម្របសម្រួលដល់ជនរងគ្រោះដែលជាសមាជិកបេឡាជាតិសន្តិសុខសង្គមឱ្យមានការសម្រាកព្យាបាល និងមានភាពងាយស្រួលក្នុងការទទួលបានសេវាថែទាំសុខភាពដែលមាននៅជិតកន្លែង។

ជាក់ស្តែង ដោយបានមើលឃើញនូវអត្ថប្រយោជន៍នៃបេឡាជាតិសន្តិសុខសង្គម ដែលបានផ្តល់ចំពោះសេដ្ឋកិច្ចជាតិ និងប្រជាជនបែបនេះហើយ ទើបបានជាក្រុមនាងខ្ញុំបានសម្រេចចិត្តធ្វើការស្រាវជ្រាវលម្អិតបន្ថែមអំពីប្រធានបទ"**អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គម**" ដើម្បីបង្កើននូវការយល់ដឹងបន្ថែមពីបេឡាជាតិសន្តិសុខសង្គម និងទុកជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយៗ ដើម្បីធ្វើការស្រាវជ្រាវបន្ត។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ជាក់ស្តែង ប្រទេសកម្ពុជាសព្វថ្ងៃគឺជាប្រទេសកំពុងមានការអភិវឌ្ឍទៅលើវិស័យជាច្រើន ដើម្បីឆ្ពោះទៅរកភាពរីកចម្រើន។ ហើយបេឡាជាតិសន្តិសុខសង្គមដែលជាដៃគូសហការជាមួយវិស័យសុខាភិបាលក៏បានចូលរួម

ជាច្រើនក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងបានចូលរួមជួយក្នុងការសម្របសម្រួលដល់ជីវភាពរស់នៅ និងជួយកាត់បន្ថយភាពក្រីក្រប្រជាជនផងដែល។ បេឡាជាតិសន្តិសុខសង្គមបានផ្តល់ជូនសេវាថែទាំសុខភាព និងហានិភ័យការងារដល់ប្រជាជន និងជនទាំងឡាយស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារនៅតាមបណ្តាលសហគ្រាស និងគ្រឹះស្ថាននានា ដែលជាសមាជិកបេឡាជាតិសន្តិសុខសង្គម។ ដូច្នេះហើយឆ្លងតាមការបកស្រាយប្រធានបទខាងលើ ក្រុមនាងខ្ញុំក៏មានសំណួរមួយចំនួនដែលបានលើកឡើងដើម្បីចោទជាបញ្ហាដូចខាងក្រោមៈ

១. តើលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គមមានអ្វីខ្លះ?

២. តើការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គមបានផ្តល់អត្ថប្រយោជន៍អ្វីខ្លះ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវគឺ ឆ្លុះបញ្ចាំងពីប្រសិទ្ធិភាពក្នុងការបង្កើតបេឡាជាតិសន្តិសុខសង្គមដោយផ្តោតទៅលើចំណុចសំខាន់មួយចំនួនដូចជា

- ការស្វែងយល់ពីចក្ខុវិស័យ និងបេសកកម្មរបស់បេឡាជាតិសន្តិសុខសង្គម
- ដើម្បីធានាឲ្យមានសមធម៌និងសាមគ្គីធម៌ និងដើម្បីលើកកម្ពស់សុខុមាលភាពនិងជីវភាពរបស់ប្រជាពលរដ្ឋព្រមទាំងធានាអត្ថិភាពការងារជានិរន្តរក្នុងគោលដៅការពារផលប្រយោជន៍ផ្នែកសន្តិសុខសង្គមដល់សមាជិករបស់ខ្លួន
- ការអនុវត្តបេឡាជាតិសន្តិសុខសង្គមផ្នែកសេវាថែទាំសុខភាព និងហានិភ័យការងារ
- ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយរបស់បេឡាជាតិសន្តិសុខសង្គម
- យល់ដឹងពីការចុះបញ្ជី ការបង់ភាគទាន និងនីតិវិធីបង់ភាគទានរបស់បេឡាជាតិសន្តិសុខសង្គម
- យល់ដឹងពីអត្ថប្រយោជន៍នៃការចូលជាសមាជិករបស់បេឡាជាតិសន្តិសុខសង្គម
- សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍មួយចំនួនដើម្បីកែលម្អចំណុចខ្វះខាតដែលពុំទាន់ពេញលេញ និងសមស្របប្រសិនបើមាន។

## ១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ការស្រាវជ្រាវទៅលើប្រធានបទស្តី "**អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គម**" យើងផ្តោតសំខាន់ទៅលើប្រជាជន និងជនទាំងឡាយស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារនៅតាមបណ្តាលសហគ្រាស និងគ្រឹះស្ថាននានាដែលទទួលបានសេវាថែទាំសុខភាព និងហានិភ័យការងារតែប៉ុណ្ណោះដែលមានទីស្នាក់ការកណ្តាលរបស់បេឡាជាតិសន្តិសុខសង្គមមានអាស័យដ្ឋានស្ថិតនៅ ផ្លូវបេតុង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

### ១.៤.២ វិសាលភាព

ការសិក្សាស្រាវជ្រាវប្រធានបទខាងលើនេះគឺតម្រូវឱ្យមានវិសាលភាពច្បាស់លាស់។ ហើយការសិក្សាស្រាវជ្រាវប្រធានបទខាងលើនេះគឺផ្តោតទៅលើការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គមនៅក្នុងកំឡុងឆ្នាំ២០២២ យកមកធ្វើការបកស្រាយតែប៉ុណ្ណោះ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវប្រធានបទខាងលើនេះត្រូវបានប្រើតាមវិធីសាស្ត្របែបគុណវិស័យ (Qualitative Methods) ដោយផ្តោតចម្បងទៅលើការប្រមូលទិន្នន័យ និងឯកសារដែលពាក់ព័ន្ធបានមកពីបេឡាជាតិសន្តិសុខសង្គម ដើម្បីយកមកបកស្រាយ និងសិក្សាស្រាវជ្រាវក្នុងគោលបំណងបញ្ជាក់នៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គម។

**សម្រាប់សំណួរទី១** ក្នុងការស្រាវជ្រាវគឺជ្រើសរើសយកវិធីសាស្ត្រតាមបែបគុណវិស័យ(Qualitative Research)ដោយផ្តោតសំខាន់ទៅលើប្រភពទិន្នន័យបន្ទាប់បន្សំ(Secondary Data) រួមមានដូចជា ឯកសារដែលមាននៅក្នុង (website) របស់បេឡាជាតិសន្តិសុខសង្គម ឯកសារតាមរយៈ(Google) ដែលមានទិន្នន័យពាក់ព័ន្ធនឹងបេឡាជាតិសន្តិសុខសង្គម ការសាកសួរព័ត៌មាន និងការសម្ភាសន៍ទៅលើផ្នែកលេខាធិការបេឡាជាតិសន្តិសុខសង្គមដោយផ្ទាល់ រួមទាំងឯកសារពាក់ព័ន្ធផ្សេងៗទៀត។

**សម្រាប់សំណួរទី២** ក្នុងការស្រាវជ្រាវគឺជ្រើសរើសយកវិធីសាស្ត្រតាមបែបគុណវិស័យ(Qualitative Research)ដោយផ្តោតសំខាន់ទៅលើប្រភពទិន្នន័យបន្ទាប់បន្សំ(Secondary Data)រួមមានដូចជា ឯកសារតាមរយៈ(Google) ដែលមានទិន្នន័យពាក់ព័ន្ធឯកសារមួយចំនួនផ្សេងទៀតបានមកពីបណ្ណាល័យសកលវិទ្យាល័យវ៉ាន់ដា និងការសុំជាការផ្តល់មតិយោបល់ការណែនាំពីអ្នកគ្រូណែនាំនៃការស្រាវជ្រាវផងដែរ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

តាមការសិក្សាស្រាវជ្រាវប្រធានបទនេះពិតជាបានផ្តល់នូវសារៈសំខាន់ និងអត្ថប្រយោជន៍ជាច្រើនដល់យើង ជាពិសេសនោះគឺ៖

### ១.៦.១ សារៈសំខាន់នៃការស្រាវជ្រាវចំពោះក្រុមអ្នកស្រាវជ្រាវផ្ទាល់

១. ការអភិវឌ្ឍន៍ចំណេះដឹង និងជំនាញផ្ទាល់ខ្លួន

❖ ពង្រីកចំណេះដឹងអំពីសុខភាព និងសុវត្ថិភាពការងារ៖

- អ្នកនឹងបានសិក្សាអំពីគ្រោះថ្នាក់សុខភាពដែលកើតពីការងារ និងវិធីការពារ។
- យល់ដឹងពីប្រព័ន្ធសេវាសុខភាពសម្រាប់កម្មករ និងអ្នកធ្វើការនៅកម្ពុជា។

❖ ពង្រីកជំនាញស្រាវជ្រាវ៖

- បង្កើនសមត្ថភាពក្នុងការប្រមូលទិន្នន័យ វិភាគបញ្ហា និងស្វែងរកដំណោះស្រាយ។
- អាចអនុវត្តវិធីសាកសួរ ស្ទង់មតិ ឬសិក្សាករណីវិភាគ។

២. ការលើកកម្ពស់ឱកាសអាជីព និងការងារ

❖ ការស្រាវជ្រាវនេះអាចបើកផ្លូវអាជីពថ្មីៗ៖

- អាចក្លាយជាអ្នកឯកទេសផ្នែកសុវត្ថិភាពការងារ ឬសុខភាពសង្គម។
- មានឱកាសធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាល (NGO) ឬអង្គការអន្តរជាតិដែលផ្តោតលើសុខភាពកម្មករ។

❖ ជាឯកសារយោងសម្រាប់ការសិក្សាបន្ត៖

- អាចប្រើលទ្ធផលស្រាវជ្រាវនេះជាមូលដ្ឋានសម្រាប់ការសរសេរស្នាដៃ ឬការស្រាវជ្រាវកម្រិតខ្ពស់ជាង។

៣. ការចូលរួមចំណែកដល់សង្គម

❖យើងអាចក្លាយជាអ្នកលើកកម្ពស់យុត្តិធម៌សង្គម៖

- ដោយជួយឱ្យបេឡាសន្តិសុខសង្គមទទួលបានសេវាសុខភាព និងការការពារកាន់តែប្រសើរ។

- លទ្ធផលស្រាវជ្រាវអាចជួយឱ្យអ្នកធ្វើការផ្សេងៗទៀតក្នុងសង្គមទទួលបានអត្ថប្រយោជន៍ស្រដៀងគ្នា។

❖ការទទួលបានការទទួលស្គាល់៖

- ប្រសិនបើការស្រាវជ្រាវនេះមានភាពជាក់លាក់ អ្នកអាចទទួលបានការគាំទ្រពីស្ថាប័ន ឬអង្គការពាក់ព័ន្ធ។

៤. ការអភិវឌ្ឍន៍ផ្ទាល់ខ្លួន

❖ ការកែលម្អសមត្ថភាពវិភាគ និងដោះស្រាយបញ្ហា៖

- អ្នកនឹងរៀនពីការកំណត់បញ្ហា ការស្វែងរកដំណោះស្រាយ និងការផ្តល់អនុសាសន៍។

❖ ការបង្កើតបណ្តាញទំនាក់ទំនង៖

- អាចស្គាល់អ្នកជំនាញ និងអ្នកដឹកនាំក្នុងវិស័យសុខភាព និងសុវត្ថិភាពការងារ។

**១.៦.២ សារៈសំខាន់នៃការស្រាវជ្រាវចំពោះស្ថានប័ន**

១. ការលើកកម្ពស់ប្រសិទ្ធភាពការងារ និងផលិតភាព

❖ កាត់បន្ថយអវត្តមានកម្មករ៖ ដោយសារបុគ្គលិកមានសុខភាពល្អ និងទទួលបានការព្យាបាលពេលមានបញ្ហាសុខភាព ស្ថាប័នអាចកាត់បន្ថយថ្ងៃឈប់សម្រាកដោយសារជំងឺ។

❖ បង្កើនផលិតភាព៖ ការថែទាំសុខភាពប្រកបដោយប្រសិទ្ធភាពជួយឱ្យបុគ្គលិកមានសុខភាពធានា និងអាចផ្តោតលើការងារបានល្អ។

២. ការគ្រប់គ្រងហានិភ័យ និងសុវត្ថិភាពការងារ

❖ ការកំណត់ហានិភ័យសុខភាព៖ ការស្រាវជ្រាវនេះអាចជួយស្ថាប័នរកឃើញបញ្ហាសុខភាព និងហានិភ័យការងារដែលបុគ្គលិកអាចជួបប្រទះ ដូចជា៖

- គ្រោះថ្នាក់ចរាចរណ៍ (សម្រាប់បុគ្គលិកបេឡាជាតិសន្តិសុខសង្គមដែលធ្វើការតាមដងផ្លូវ)។

- ជំងឺដែលកើតពីបរិស្ថានការងារមិនសុវត្ថិភាព។

❖ ការរៀបចំផែនការការពារ៖ ស្ថាប័នអាចបង្កើតគោលនយោបាយ និងកម្មវិធីសុវត្ថិភាពការងារដោយផ្អែកលើលទ្ធផលស្រាវជ្រាវ។

៣. ការកែលម្អសេវាកម្មសុខភាពសម្រាប់បុគ្គលិក

❖ ធានាសេវាសុខភាពដែលមានគុណភាព៖ ការស្រាវជ្រាវនេះអាចជួយស្ថាប័នវាយតម្លៃប្រសិទ្ធភាពសេវាសុខភាពដែលបានផ្តល់ និងធ្វើឱ្យវាកាន់តែមានប្រសិទ្ធភាព។

❖ ការផ្តល់សេវាបន្ថែមដូចជា៖

- ការពិនិត្យសុខភាពប្រចាំឆ្នាំ។

- ការបណ្តុះបណ្តាលអំពីសុវត្ថិភាពការងារ។

- ការគាំទ្រផ្នែកផ្លូវចិត្តសម្រាប់បុគ្គលិក។

៤. ការអភិវឌ្ឍគោលនយោបាយ និងយុត្តិធម៌សង្គម

❖ ការបង្កើតគោលនយោបាយថ្មី៖ លទ្ធផលស្រាវជ្រាវអាចជាមូលដ្ឋានសម្រាប់ការរៀបចំគោលនយោបាយសុវត្ថិភាពការងារ និងសុខភាពបុគ្គលិក។

❖ ការលើកកម្ពស់យុត្តិធម៌សង្គម៖ ដោយធានាថាបុគ្គលិកទទួលបានសេវាសុខភាពយុត្តិធម៌ និងមានសុវត្ថិភាពក្នុងការងារ។

៥. ការកាត់បន្ថយការចំណាយដោយសារបញ្ហាសុខភាព

❖ កាត់បន្ថយការចំណាយលើការព្យាបាល៖ ការប្រើប្រាស់សេវាសុខភាពឱ្យបានទាន់ពេលអាចជួយកាត់បន្ថយការចំណាយលើការព្យាបាលដែលថ្លៃថ្នូរ។

❖ ជៀសវាងការបង់សំណងដោយសារគ្រោះថ្នាក់ការងារ៖ ការកាត់បន្ថយហានិភ័យការងារអាចជួយស្ថាប័នជៀសវាងការបង់សំណងដល់បុគ្គលិកដែលរងរបួសក្នុងការងារ។

**១.៦.៣ សារៈសំខាន់នៃការស្រាវជ្រាវចំពោះសង្គម**

១. ការលើកកម្ពស់សុខភាពសាធារណៈ

❖ បង្ការជំងឺឆ្លង និងជំងឺដែលកើតពីការងារ៖ ការសិក្សាអំពីហានិភ័យសុខភាពរបស់បេឡាអាចជួយកាត់បន្ថយការរាលដាលនៃជំងឺដែលអាចផ្ទុះជាបណ្តាញសង្គម។

❖ លើកកម្ពស់ការយល់ដឹងអំពីសុខភាព៖ បង្កើនចំណេះដឹងរបស់សាធារណៈជនអំពីសុវត្ថិភាពការងារ និងសារៈសំខាន់នៃការពិនិត្យសុខភាពទៀងទាត់។

២. ការកាត់បន្ថយអត្រាគ្រោះថ្នាក់ និងពិការភាពការងារ

❖ ការពារជីវិតមនុស្ស៖ ការស្រាវជ្រាវនេះអាចជួយដាក់ចេញវិធីសាកសួរដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងគ្រោះថ្នាក់ការងារដទៃទៀតដែលបេឡាជាតិសន្តិសុខសង្គមជួបប្រទះ។

❖ កាត់បន្ថយអត្រាពិការភាព៖ ដោយធានាថាបុគ្គលិកទទួលបានការថែទាំសុខភាពល្អ សង្គមអាចកាត់បន្ថយចំនួនមនុស្សដែលបាត់បង់សមត្ថភាពការងារដោយសារជំងឺ ឬរបួស។

៣. ការលើកកម្ពស់សមភាពសង្គម និងការគាំទ្រអ្នកធ្វើការ

❖ ធានាសិទ្ធិសុខភាពរបស់កម្មករ៖ ការស្រាវជ្រាវនេះអាចជួយលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិសុខភាពរបស់អ្នកធ្វើការ និងជម្រុញឱ្យមានការអនុវត្តគោលនយោបាយល្អប្រសើរឡើង។

❖ លើកកម្ពស់យុត្តិធម៌សង្គម៖ ដោយធានាថាបេឡាសន្តិសុខសង្គម ដែលជាក្រុមអ្នកធ្វើការមានហានិភ័យខ្ពស់ ទទួលបានសេវាសុខភាពដែលគ្រប់គ្រាន់ និងមានគុណភាព។

៤. ការអភិវឌ្ឍន៍យោបាយសង្គម និងសេដ្ឋកិច្ច

❖ ការកែលម្អគោលនយោបាយសុខភាពជាតិ៖ លទ្ធផលស្រាវជ្រាវអាចជាមូលដ្ឋានសម្រាប់រដ្ឋាភិបាលក្នុងការរៀបចំយុទ្ធសាស្ត្រថែទាំសុខភាព និងសុវត្ថិភាពការងារសម្រាប់ក្រុមអ្នកធ្វើការទាំងអស់។

❖ កាត់បន្ថយអត្រាភាពក្រីក្រ៖ ដោយការពារសុខភាពអ្នកធ្វើការ សង្គមអាចកាត់បន្ថយអត្រាការបាត់បង់ប្រាក់ចំណូលដោយសារជំងឺ ឬពិការភាព ដែលជាកត្តាសំខាន់ក្នុងការបង្កើនសមត្ថភាពសេដ្ឋកិច្ច។

៥. ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជន

❖ បង្កើនសុខភាពរបស់គ្រួសារ៖ នៅពេលដែលបេឡាជាតិសន្តិសុខសង្គមមានសុខភាពល្អ ពួកគេអាចថែទាំគ្រួសារបានល្អជាងមុន ដែលជាកត្តាសំខាន់ក្នុងការលើកកម្ពស់សុខភាពសង្គមទូទៅ។

❖ ជំរុញឱ្យមានការងារមានសុវត្ថិភាព៖ ការស្រាវជ្រាវនេះអាចជាគំរូសម្រាប់វិស័យការងារផ្សេងៗទៀតក្នុងការការពារសុខភាពអ្នកធ្វើការ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវប្រធានបទស្តីពី "អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គម" នេះក្រុមនាងខ្ញុំបានបែងចែកចេញជា ៥ជំពូកគឺ៖

**ជំពូកទី១៖ សេចក្តីផ្តើម**

ណែនាំអំពីប្រធានបទដែលនឹងពិភាក្សា បកស្រាយអំពីសារៈសំខាន់ឬហេតុផលនៃការសិក្សាប្រធានបទនេះ បញ្ជាក់អំពីដែនកំណត់ ឬក្របខណ្ឌនៃការពិភាក្សា ផ្តល់ទិដ្ឋភាពសរុបសង្ខេបអំពីអ្វីដែលនឹងមានក្នុងអត្ថបទ។

**ជំពូកទី២៖ អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងារ**

បង្ហាញពី និយមន័យ ប្រវត្តិ និងទ្រឹស្តីពាក់ព័ន្ធនឹងប្រធានបទ។

**ជំពូកទី៣៖ លទ្ធផលនៃការស្រាវជ្រាវ**

ទិន្នន័យដែលបានរកឃើញក្នុងអំឡុងពេលស្រាវជ្រាវ ការពន្យល់អំពីអត្ថន័យនៃលទ្ធផល និងទំនាក់ទំនងរបស់វាជាមួយនឹងទ្រឹស្តីឬការសិក្សាពីមុន ។

**ជំពូកទី៤៖ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ**

ការវិភាគ និងស្វែងយល់បន្ថែមទៅលើចំណុចខ្លាំង និងចំណុចខ្សោយរបស់ប្រធានបទ។

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**

សង្ខេបលទ្ធផលសំខាន់ៗ ការបកស្រាយទាក់ទងនឹងគោលបំណងស្រាវជ្រាវ ការបញ្ជាក់ពីសារៈប្រយោជន៍នៃការសិក្សា ដែនកំណត់នៃការសិក្សា អនុសាសន៍សម្រាប់ការអនុវត្ត អនុសាសន៍សម្រាប់ការស្រាវជ្រាវបន្ត និងអនុសាសន៍ដល់អ្នកពាក់ព័ន្ធ។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២

# អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងារ

## ២.១ លក្ខណៈទូទៅនៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងារ

### ២.១.១ និយមន័យថែទាំសុខភាព

ថែទាំសុខភាព (Health Maintenance) អាចមានភាពខុសគ្នាទៅតាមទស្សនៈរបស់អ្នកជំនាញ និងអង្គការផ្សេងៗ។ ខាងក្រោមនេះគឺជានិយមន័យសំខាន់ៗដែលទាក់ទងនឹងថែទាំសុខភាព៖

**ថែទាំសុខភាព** គឺជាការផ្តល់សេវាដល់បុគ្គល ឬសហគមន៍ ដើម្បីលើកកម្ពស់ ការពារ ឬស្តារសុខភាព និងការព្យាបាលជំងឺ។ វារួមមានការថែទាំសុខភាពផ្នែករាងកាយ ផ្លូវចិត្ត និងសង្គម[1]។

**ថែទាំសុខភាព** គឺជាការជួយឱ្យអ្នកជំងឺមានសុខភាពល្អ និងការពារជំងឺតាមរយៈការគ្រប់គ្រងបរិស្ថានដែលមានអនាម័យ និងសុវត្ថិភាព[2]។

**ថែទាំសុខភាព** គឺជាការការពារ លើកកម្ពស់ និងស្តារសុខភាពរបស់បុគ្គល គ្រួសារ សហគមន៍ និងប្រជាជនទាំងមូល។ វារួមមានការផ្តល់សេវាថែទាំដែលផ្តោតលើតម្រូវការរបស់អ្នកជំងឺ និងការគាំទ្រផ្លូវចិត្ត[3]។

**ថែទាំសុខភាព** គឺជាការជួយឱ្យបុគ្គលមានសមត្ថភាពថែទាំខ្លួនឯង និងគាំទ្រនៅពេលដែលពួកគេមិនអាចថែទាំខ្លួនឯងបាន[4]។

**ថែទាំសុខភាព** គឺជាការផ្តល់សេវាដែលផ្តោតលើការការពារ ការព្យាបាល និងការលើកកម្ពស់សុខភាព និងសុខុមាលភាពរបស់បុគ្គល គ្រួសារ និងសហគមន៍[5]។

### ២.១.២ ប្រវត្តិថែទាំសុខភាព

ប្រវត្តិថែទាំសុខភាព (Health Maintenance) មានដើមកំណើតពីសម័យបុរាណ ហើយបានវិវត្តន៍តាមរយៈសម័យកាលផ្សេងៗ។ ខាងក្រោមនេះគឺជាការសង្ខេបអំពីប្រវត្តិថែទាំសុខភាព៖

**១. សម័យបុរាណ**

- សម័យអេហ្ស៊ីបបុរាណ (ប្រហែល ៣០០០-៣០០ ឆ្នាំមុនគ.ស.)៖ Papyrus Ebers (ប្រហែល ១៥៥០ ឆ្នាំមុនគ.ស.) បានចារអំពីការព្យាបាលជំងឺ និងការប្រើប្រាស់ថ្នាំពេទ្យពីរុក្ខជាតិ[6]។

- សម័យក្រិកបុរាណ (ប្រហែល ៨០០-៣០០ ឆ្នាំមុនគ.ស.)៖ ហ៊ីប៉ូក្រាត (Hippocrates) បានចារក្នុងសៀវភៅ Corpus Hippocraticum អំពីសារៈសំខាន់នៃការថែទាំសុខភាព និងអនាម័យ[7]។

[1] World Health Organization (WHO). (1948/April/07). https://www.who.int

[2] Florence Nightingale (1859) Notes on Nursing. What It Is and What It Is Not. https://www.nationalarchives.gov.uk

[3] American Nurses Association (ANA) (2015). Nursing Scope and Standards of Practice. https://www.nursingworld.org

[4] Dorothea Orem (1971) Nursing. Concepts of Practice. https://nurseslabs.com

[5] International Council of Nurses (ICN) (2021). ICN Definition of Nursing. http://www.icn.ch

[6] Ebers Papyrus (1875). The Papyrus Ebers ទំព័រទី១-១១០ https://en.m.wikipedai.org

[7] Hippocratic Corpus (1525). The Genuine Works of Hippocrates ទំព័រទី១-៥០ https://en.m.wikipedai.org

### ២. សម័យមជ្ឈិមសម័យ

- សម័យអ៊ីស្លាម (សតវត្សទី ៧-១៥)៖អ្នកវិទ្យាសាស្ត្រដូចជា អាវីសេន្នា (Avicenna) បានសរសេរសៀវភៅ The Canon of Medicine (ប្រហែលឆ្នាំ ១០២៥) ដែលជាគោលការណ៍វេជ្ជសាស្ត្រសំខាន់[8]។

- សម័យអឺរ៉ុប (សតវត្សទី ៥-15)៖ Materia Medica របស់ Dioscorides (សតវត្សទី១) បានផ្តល់ព័ត៌មានអំពីថ្នាំពេទ្យពីរុក្ខជាតិ[9]។

### ៣. សម័យទំនើប

- សតវត្សទី១៩៖ Florence Nightingale បានអភិវឌ្ឍន៍ទ្រឹស្តីអំពីការថែទាំសុខភាព និងបានសរសេរសៀវភៅ Notes on Nursing (១៨៥៩)[10]។

- សតវត្សទី ២០៖ ការបង្កើតអង្គការសុខភាពពិភពលោក (World Health Organization) នៅថ្ងៃទី ៧ ខែមេសា ឆ្នាំ ១៩៤៨ បានធ្វើឱ្យមានការសហការអន្តរជាតិក្នុងការការពារ និងពង្រីកសុខភាពសាធារណៈ[11]។

### ៤. សម័យបច្ចុប្បន្ន

- សតវត្សទី ២១៖ ការអភិវឌ្ឍនៃបច្ចេកវិទ្យាសុខភាពឌីជីថល និងការបង្កើតថ្នាំប្រឆាំងជំងឺថ្មីៗ បានធ្វើឱ្យការថែទាំសុខភាពកាន់តែទំនើប[12]។ ឧទាហរណ៍៖ ការអភិវឌ្ឍវ៉ាក់សាំងប្រឆាំង COVID-១៩ នៅឆ្នាំ២០២០-២០២១។ ប្រវត្តិនៃការថែទាំសុខភាពបានចាប់ផ្តើមពីសម័យបុរាណ ហើយបានវិវត្តន៍តាមរយៈការរីកចម្រើននៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាបានជួយឱ្យមនុស្សជាតិមានសុខភាពល្អប្រសើរឡើង។

### ២.១.៣ ទ្រឹស្តីថែទាំសុខភាព

ទ្រឹស្តីថែទាំសុខភាព គឺជាទ្រឹស្តីដែលផ្តោតលើការថែទាំសុខភាព ការការពារ និងការលើកកម្ពស់សុខភាពរបស់មនុស្ស។ ទ្រឹស្តីនេះត្រូវបានអភិវឌ្ឍន៍ឡើងដោយអ្នកជំនាញផ្នែកសុខភាព និងវិទ្យាសាស្ត្រសង្គម ដើម្បីផ្តល់គោលការណ៍ និងវិធីសាស្ត្រសម្រាប់ការថែទាំអ្នកជំងឺ និងការលើកកម្ពស់សុខភាពជាទូទៅ។ ខាងក្រោមនេះគឺជាទ្រឹស្តីសំខាន់ៗខ្លះនៅក្នុងថែទាំសុខភាព៖

### ១. ទ្រឹស្តីនៃការថែទាំ (Nursing Theories)

ទ្រឹស្តីនៃការថែទាំត្រូវបានអភិវឌ្ឍន៍ដោយអ្នកជំនាញផ្នែកថែទាំ ដើម្បីផ្តល់គោលការណ៍សម្រាប់ការថែទាំអ្នកជំងឺ។

- ទ្រឹស្តីរបស់ Florence Nightingale (១៨៥៩)៖ ផ្តោតលើបរិស្ថានជុំវិញអ្នកជំងឺ ដែលអាចជះឥទ្ធិពលលើសុខភាព[13]។

- ទ្រឹស្តីរបស់ Dorothea Orem (១៩៧១) ៖ ផ្តោតលើការថែទាំខ្លួនឯង (Self-Care Deficit Nursing Theory)[14]។

-ទ្រឹស្តីរបស់ Jean Watson (១៩៧៩) ៖ ផ្តោតលើការថែទាំដោយស្នេហា និងការយកចិត្តទុកដាក់ (Theory of Human Caring)[15]។

---

[8] The Canon of Medicine (1473). Avicenna´s Medicine ទំព័រ ១-១០០០ https://en.m.wikipedia.org

[9] De Materia Medica (1478).Google Books: De Materia Medica ទំព័រ ១-៥០០ https://books.google.com.kh

[10] Florence Nightingale (1859). Notes on Nursing :What It Is and What It Is Not ទំព័រ ១-100 https://books.google.com.kh

[11] Constitution of the World Health Organization(07/April/1948). Worl Health Assembly ទំព័រ ១-២០ https://www.who.int

[12] World Health Organization (WHO) reports on COVID-19 vaccines(2020-2021) ទំព័រ ១-៥០ https://www.who.int

[13] The National Archives(02/April/2003). Public Records Act https://www.nationalarchives.gov.uk

[14] Paul Martin RN (2012-2014). Nurseslabs https://nurseslabs.com

[15] Davi Bourget and David Chalmers (2009). Philpapers https://philpapers.org

**២. ទ្រឹស្តីនៃការលើកកម្ពស់សុខភាព (Health Promotion Theories)**

ទ្រឹស្តីទាំងនេះផ្តោតលើការលើកកម្ពស់សុខភាព និងការការពារជំងឺ។

- ទ្រឹស្តីរបស់ Nola Pender (១៩៨២)៖ Health Promotion Model ដែលផ្តោតលើកត្តាផ្ទាល់ខ្លួន និងបរិស្ថានដែលជះឥទ្ធិពលលើសុខភាព[16]។

- ទ្រឹស្តីរបស់ Albert Bandura (១៩៧៧)៖ Social Cognitive Theory ដែលផ្តោតលើការរៀនសូត្រតាមរយៈការសង្កេត និងការគ្រប់គ្រងខ្លួនឯង[17]។

**៣. ទ្រឹស្តីនៃការផ្លាស់ប្តូរឥរិយាបថ (Behavioral Change Theories)**

ទ្រឹស្តីទាំងនេះផ្តោតលើការផ្លាស់ប្តូរឥរិយាបថដើម្បីលើកកម្ពស់សុខភាព។

- ទ្រឹស្តីរបស់ Prochaska និង DiClemente (១៩៨៣)៖ Transtheoretical Model (Stages of Change) ដែលពិពណ៌នាអំពីដំណាក់កាលនៃការផ្លាស់ប្តូរឥរិយាបថ[18]។

- ទ្រឹស្តីរបស់ Becker (១៩៧៤)៖ Health Belief Model ដែលផ្តោតលើការយល់ដឹងអំពីគ្រោះថ្នាក់សុខភាព និងការទទួលយកការប្រកាន់ឥរិយាបថសុខភាព[19]។

**៤. ទ្រឹស្តីនៃការថែទាំផ្ទាល់ខ្លួន (Self-Care Theories)**

ទ្រឹស្តីទាំងនេះផ្តោតលើសមត្ថភាពរបស់មនុស្សក្នុងការថែទាំខ្លួនឯង។

- ទ្រឹស្តីរបស់ Dorothea Orem (១៩៧១)៖ Self-Care Deficit Nursing Theory ដែលផ្តោតលើការថែទាំខ្លួនឯង និងការគាំទ្រពីអ្នកជំនាញ[20]។

**៥. ទ្រឹស្តីនៃការថែទាំផ្តោតលើគ្រួសារ (Family-Centered Care Theories)**

ទ្រឹស្តីទាំងនេះផ្តោតលើការថែទាំដែលពាក់ព័ន្ធនឹងគ្រួសារ។

- ទ្រឹស្តីរបស់ Betty Neuman (១៩៧២)៖ Neuman Systems Model ដែលផ្តោតលើការថែទាំដោយពិចារណាលើប្រព័ន្ធសង្គម និងគ្រួសារ[21]។

## ២.២ លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងារ

### ២.២.១ និយមន័យហានិភ័យការងារ

**ហានិភ័យការងារ** សំដៅដល់ព្រឹត្តិការណ៍ដែលកើតឡើងដោយឥតគ្រោងទុកបណ្តាលមកពី គ្រោះថ្នាក់ការងារ គ្រោះថ្នាក់ក្នុងពេលធ្វើដំណើរ និងជំងឺវិជ្ជាជីវៈ[22]។

**គ្រោះថ្នាក់ការងារ** សំដៅដល់គ្រោះថ្នាក់ដែលកើតឡើងដោយចៃដន្យ និងភ្លាមៗក្នុងអំឡុងពេលបំពេញការងារ ឬនៅកន្លែងធ្វើការងារដោយមូលហេតុទាក់ទងនឹងកំហុសជនរងគ្រោះ ឬគ្មានកំហុសក៏ដោយដែលបណ្តាលឱ្យជនរងគ្រោះទទួលរងរបួសស្នាមជាយថាហេតុ។

---

[16] Nurseslabs (12/May/2014) Wayback Machine(Internet Archive) https://nurseslabs.com
[17] Dr. Sauul McLeod (2007) SimplyPsychology https://www.simplypsychology.org
[18] American Psychological Association, APA (1994) APA PsycNet https://psycnet.apa.org
[19] Scientific Research. Becker (1974) https://www.scrip.org
[20] Nurseslabs. Dorothea Orem (1971) https://nurseslabs.com
[21] Nurseslabs. Betty Neuman (1972) https://nurseslabs.com
[22] Nation Social Security Fud(01/January/2024) ផ្នែកហានិភ័យការងារ https://www.nssf.gov.kh

**ហានិភ័យការងារ** គឺជាការប្រឈមមុខនឹងហានិភ័យ ឬការខាតបង់ដែលអាចកើតមានក្នុងការងារ ឬក្នុងព្រឹត្តិការណ៍ផ្សេងៗដែលទាក់ទងនឹងការងារ។ ហានិភ័យទាំងនេះអាចរួមមានការបាត់បង់ហិរញ្ញវត្ថុ ការខូចខាតដល់ទ្រព្យសម្បត្តិ ឬការប៉ះពាល់ដល់សុខភាព និងសុវត្ថិភាពរបស់បុគ្គលិក។ ប្រភពនៃហានិភ័យការងារអាចមកពី៖

- កត្តាខាងក្នុង៖ ដូចជាការគ្រប់គ្រងខ្សោយ ការប្រើប្រាស់បច្ចេកវិទ្យាមិនត្រឹមត្រូវ ឬការបរាជ័យក្នុងការអនុវត្តនូវគោលនយោបាយសុវត្ថិភាព។
- កត្តាខាងក្រៅ៖ ដូចជាការប្រែប្រួលនៃទីផ្សារ ការផ្លាស់ប្តូរច្បាប់ចម្លង ឬការកើតឡើងនូវគ្រោះមហន្តរាយធម្មជាតិ។

**ហានិភ័យការងារ** គឺជាការព្យាករណ៍ ឬលទ្ធភាពនៃការកើតមាននូវស្ថានភាពអវិជ្ជមាន ឬវិបត្តិដែលអាចប៉ះពាល់ដល់ការសម្រេចគោលដៅការងារ សុខភាព សុវត្ថិភាព ឬប្រសិទ្ធភាពនៃការងារនៅក្នុងអង្គការ។ ហានិភ័យការងារអាចមានដូចជា៖

- ហានិភ័យសុខភាព និងសុវត្ថិភាព (ឧទាហរណ៍៖ គ្រោះថ្នាក់ការងារ)
- ហានិភ័យហិរញ្ញវត្ថុ (ឧទាហរណ៍៖ ការខាតបង់ថវិកា)
- ហានិភ័យប្រតិបត្តិការ (ឧទាហរណ៍៖ ការរាំងស្ទះដែនការងារ)
- ហានិភ័យបរិស្ថាន (ឧទាហរណ៍៖ ការបំពុល)
- ហានិភ័យច្បាប់ (ឧទាហរណ៍៖ ការប្តឹងចំពោះការងារ)

### ២.២.២ ប្រវត្តិហានិភ័យការងារ

ប្រវត្តិហានិភ័យការងារបានបង្ហាញពីការកើតមានក្នុងការអភិវឌ្ឍន៍នៃគំនិត និងវិធីសាស្ត្រដើម្បីការពារ និងកាត់បន្ថយហានិភ័យនៅក្នុងទីកន្លែងធ្វើការ។ ខាងក្រោមនេះគឺជាចំណុចសំខាន់ៗនៃប្រវត្តិនេះ៖

**១. សម័យចាប់ផ្តើម**

- សម័យអាណាចក្រ៖ នៅក្នុងសម័យនេះ មនុស្សធ្វើការជាមួយឧបករណ៍ធម្មជាតិ និងគ្មានការពារ។ គ្រោះថ្នាក់បានកើតឡើងជាញឹកញាប់ ដោយគ្មានច្បាប់ ឬគោលការណ៍ណាមួយ។
- សម័យវិស័យរោងចក្រ៖ នៅសម័យរោងចក្រ (១៨-១៩ សតវត្ស) ការធ្វើការនៅក្នុងរោងចក្របានកើតមានហានិភ័យជាច្រើនដូចជា ការធ្លាក់ ការបុក និងគ្រោះថ្នាក់ពីគីមី។

**២. ការបង្កើតច្បាប់សុវត្ថិភាព**

- សតវត្សទី២០៖ ជាការតាំងចិត្តដើម្បីបង្កើតច្បាប់សុវត្ថិភាពដែលអាចការពារនិយោជិក។ ប្រទេសជាច្រើនបានបង្កើតច្បាប់ដើម្បីការពារ និងធានាសុវត្ថិភាពនៅក្នុងទីកន្លែងធ្វើការ។
- (សតវត្ស១៩៤០-១៩៥០)៖ ការបង្កើតអង្គការដូចជា OSHA (Occupational Safety and Health Administration) នៅសហរដ្ឋអាមេរិក បានធ្វើឱ្យមានការកំណត់និងការត្រួតពិនិត្យលើសុវត្ថិភាពការងារ[23]។

[23] OSHA. Occupational Safety and Health Theory (29/December/1970) https://www.osha.gov

**៣. អភិវឌ្ឍន៍នៃទ្រឹស្តីហានិភ័យ**

- (សតវត្សរ៍១៩៧០-១៩៨០) ៖ មានការអភិវឌ្ឍន៍នៃទ្រឹស្តីហានិភ័យដែលផ្អែកលើវិធីសាស្ត្រនៃការវាយតម្លៃហានិភ័យ និងការគ្រប់គ្រងហានិភ័យ។ វាបានផ្តល់នូវមូលដ្ឋានសម្រាប់ការអនុវត្តន៍និងវិធានការសុវត្ថិភាព។
- (សតវត្សរ៍១៩៨០-១៩៩៩) ៖ ការបង្កើតគោលការណ៍ថ្មីៗដើម្បីបង្កើនវប្បធម៌សុវត្ថិភាព និងការចូលរួមរបស់និយោជិកក្នុងការកាត់បន្ថយហានិភ័យ។

**៤. សម័យថ្មី**

- (សតវត្សរ៍២០០០-បច្ចុប្បន្ន) ៖ មានការពង្រីក និងអភិវឌ្ឍន៍នៅលើបច្ចេកវិទ្យាថ្មីៗដូចជា ការប្រើប្រាស់ឧបករណ៍ឌីជីថល និងបច្ចេកវិទ្យា AI ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពក្នុងការការពារ និងកាត់បន្ថយហានិភ័យនៅក្នុងទីកន្លែងធ្វើការ។

ជារួមមកប្រវត្តិនៃហានិភ័យការងារ បង្ហាញពីការបង្កើតច្បាប់ និងគោលការណ៍ដែលមានគោលបំណងដើម្បីធានាសុវត្ថិភាព និងសុខភាពរបស់និយោជិក។ ការអភិវឌ្ឍន៍នេះបានធ្វើឱ្យមានកំណែប្រែដ៏សំខាន់ៗក្នុងវិធីសាស្ត្រនៃការគ្រប់គ្រងហានិភ័យនៅក្នុងទីកន្លែងធ្វើការ។

### ២.២.៣ ទ្រឹស្តីហានិភ័យការងារ

**ទ្រឹស្តីហានិភ័យការងារ** គឺជាការសិក្សា និងការអនុវត្តន៍ដើម្បីកំណត់ វាយតម្លៃ និងគ្រប់គ្រងហានិភ័យផ្សេងៗដែលអាចកើតមានក្នុងការងារ ឬបរិស្ថានការងារ។ ទ្រឹស្តីនេះផ្តោតលើការកាត់បន្ថយការខាតបង់ និងការពង្រឹងសុវត្ថិភាព និងប្រសិទ្ធភាពការងារ។ ខាងក្រោមនេះគឺជាគោលការណ៍ និងផ្នែកសំខាន់ៗនៃទ្រឹស្តីហានិភ័យការងារ៖

**១. ការកំណត់ហានិភ័យ (Risk Identification)**

- ការស្វែងរក និងកំណត់ហានិភ័យដែលអាចកើតមានក្នុងការងារ។

ឧទាហរណ៍៖ ហានិភ័យសុខភាព ហានិភ័យបច្ចេកវិទ្យា ឬហានិភ័យច្បាប់។

**២. ការវាយតម្លៃហានិភ័យ (Risk Assessment)**

- ការវិភាគពីលទ្ធភាព និងផលប៉ះពាល់នៃហានិភ័យនីមួយៗ។
- ប្រើប្រាស់វិធីសាស្ត្រដូចជា ការវាយតម្លៃប្រូបាប៊ីលីតេ (Probability) និងផលប៉ះពាល់ (Impact)។

**៣. ការគ្រប់គ្រងហានិភ័យ (Risk Management)**

- ការបង្កើតផែនការដើម្បីកាត់បន្ថយ ឬលុបបំបាត់ហានិភ័យ។
- យុទ្ធសាស្ត្ររួមមាន៖

- ការជៀសវាងហានិភ័យ (Avoidance)
- ការកាត់បន្ថយហានិភ័យ (Mitigation)
- ការផ្ទេរហានិភ័យ (Transfer) ដូចជាការទិញធានារ៉ាប់រង
- ការទទួលយកហានិភ័យ (Acceptance)[24] ។

**៤. ការតាមដាន និងពិនិត្យហានិភ័យ (Risk Monitoring and Review)** គឺការតាមដានហានិភ័យជាបន្ត និងធ្វើការពិនិត្យឡើងវិញដើម្បីធានាថាផែនការគ្រប់គ្រងហានិភ័យមានប្រសិទ្ធភាព។

[24]OSHA. Occupational Safety and Health Theory (29/December/1970) https://www.osha.gov

**៥. ការបង្កើតវប្បធម៌ហានិភ័យ (Risk Culture)** គឺការលើកកម្ពស់ការយល់ដឹងអំពីហានិភ័យក្នុងអង្គការ និងធ្វើឱ្យការគ្រប់គ្រងហានិភ័យក្លាយជាផ្នែកមួយនៃវប្បធម៌ការងារ[25]។

## ២.៣ អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គម

### ២.៣.១ និយមន័យអត្ថប្រយោជន៍

**អត្ថប្រយោជន៍** មានន័យថា អ្វីៗដែលមានប្រយោជន៍ ដែលគួរឱ្យចង់បាន។

**អត្ថប្រយោជន៍** មានន័យថា៖

ក-អំណោយអ្វីមួយ កម្ចី តម្លៃឈ្នួល រង្វាន់ ឬកម្រៃជើងសាដែលមិនមានការអនុញ្ញាតដោយច្បាប់ជាធរមាន ជាទឹកប្រាក់ ឬជាវត្ថុមានតម្លៃ ឬជាទ្រព្យសម្បត្តិប្រភេទអ្វីមួយ។

ខ-ការងារ តំណែង មុខងារ កិច្ចព្រមព្រៀង ឬកិច្ចសន្យាអ្វីមួយ។

គ-ការបង់ប្រាក់ ការលើកលែង ការលុបចោល ការលុបបំបាត់នូវប្រាក់កម្ចីអ្វីមួយ កាតព្វកិច្ច ឬបំណុលដទៃទៀត ទោះជាទាំងមូលក្តី ឬដោយផ្នែកក្តី។

ឃ-សេវាកម្មឯទៀត ឬការផ្តល់ជាគុណប្រយោជន៍ រួមទាំងកិច្ចការពារមិនឱ្យមានការដាក់ទណ្ឌកម្មដែលលេចចេញពីអំពើ ឬដំណើរការនៃការដាក់ទណ្ឌកម្មរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ទោះបីទណ្ឌកម្មនេះត្រូវបានកំណត់ ឬពុំទាន់ត្រូវបានកំណត់ក៏ដោយ។

ង-ការអនុវត្ត ឬការរារាំងមិនឱ្យអនុវត្តនូវសិទ្ធិ ឬអំណាច ឬភារកិច្ចអ្វីមួយ។

ច-ការស្នើជូន ឬការសន្យាថាជូន ទោះបីមានលក្ខខណ្ឌ ឬគ្មានលក្ខខណ្ឌក្តី នូវអត្ថប្រយោជន៍ ដូចមានចែងក្នុងស្មារតី នៃកថាខណ្ឌ (ក) (ខ) (គ) (ឃ) និង (ង)[26]។

**អត្ថប្រយោជន៍** មានន័យថា គឺជាអំណាចនៃទំនិញ ឬសេវាកម្មដើម្បីបំពេញតម្រូវការនិងចំណង់ចំណូលចិត្តរបស់អតិថិជន[27]។

### ២.៣.២ ទ្រឹស្តីអត្ថប្រយោជន៍

**ទ្រឹស្តីអត្ថប្រយោជន៍** គឺជាទ្រឹស្តីសីលធម៌ដែលកំណត់ថា សកម្មភាពណាដែលនាំមកនូវសុភមង្គល (ឬអត្ថប្រយោជន៍) អតិបរមាដល់មនុស្សច្រើនបំផុត គឺជាសកម្មភាពសីលធម៌ត្រឹមត្រូវ។ ទ្រឹស្តីនេះផ្តោតលើលទ្ធផលជាជាងគោលការណ៍អរូបី ហើយមានគោលគំនិតសំខាន់ៗដូចជា៖

**១. លទ្ធផលនិយម (Consequentialism)**៖ សកម្មភាពមួយត្រូវបានវាយតម្លៃតាមលទ្ធផលរបស់វា មិនមែនតាមគោលការណ៍ឬចរិត។

**២. គោលការណ៍សុភមង្គល (Principle of Utility)**៖ អ្វីដែលល្អគឺអ្វីដែលបង្កើនសុភមង្គល ឬកាត់បន្ថយទុក្ខវេទនា[28]។

**៣. ភាពអព្យាក្រឹត្យ (Impartiality)**៖ សុភមង្គលរបស់មនុស្សគ្រប់រូបមានតម្លៃស្មើគ្នា[29]។

---

[25] OSHA. Occupational Safety and Health Theory (29/December/1970) https://www.osha.gov
[26] Videos Learning (12/June/2023) https://videoslearning.com
[27] ទីផ្សារ (17/October/2019) http://khsearch.com
[28] An Introduction to the principles of Morals and Legislation (5/February/2018) https://www.econlib.org
[29] Utilitarianism(book) (1861) https://en.wikipedia.org

# ជំពូកទី៣
# លទ្ធផលនៃការស្រាវជ្រាវ

# ជំពូកទី៣
# អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គម

## ៣.១ ស្ថានភាពទូទៅរបស់បេឡាជាតិសន្តិសុខសង្គម

### ៣.១.១ ប្រវត្តិរបស់បេឡាជាតិសន្តិសុខសង្គម



របបសន្តិសុខសង្គមត្រូវបានរកឃើញក្នុងសតវត្សទី១៩នៅតាមបណ្ដាប្រទេសអឺរ៉ុបក្នុងទម្រង់ជំនួយសង្គមរបស់សមាគម ឬអង្គការស្ម័គ្រចិត្ត ដែលផ្ដល់ទៅឱ្យសមាជិករបស់ខ្លួន ឬជនក្រីក្រ។ ហើយរបបបេឡាជាតិសន្តិសុខសង្គម (Social Security) ត្រូវបានបង្កើតឡើងដំបូងនៅប្រទេសអាល្លឺម៉ង់ក្នុងឆ្នាំ ១៨៨៩ ដោយឯកភាពនៃការគ្រប់គ្រងសង្គមប្រព័ន្ធនេះត្រូវបានបង្កើតឡើងក្រោមការដឹកនាំរបស់ឯកសារប្រធានាធិបតីអាល្លឺម៉ង់។ នៅពេលនោះ គឺ Otto von Bismarckមានគោលបំណងនៃការបង្កើតប្រព័ន្ធសន្តិសុខសង្គមនេះគឺដើម្បីផ្ដល់ការគាំទ្រដល់អ្នកដែលមានអាយុចាស់ ឬអ្នកដែលមិនអាចធ្វើការ ដូចជាអ្នកជំងឺ ឬអ្នកដែលមានការបាត់បង់ការងារ។ យ៉ាងណាមិញ ពាក្យថា "**សន្តិសុខសង្គម**" ត្រូវបានយកមកប្រើប្រាស់ និងមានការទទួលស្គាល់ជាសកលលោកក្នុងឆ្នាំ១៩៤៨ តាមរយៈសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស មាត្រា២២ ដែលបានកំណត់ថា "មនុស្សគ្រប់រូបក្នុងនាមជាសមាជិកនៃសង្គមមានសិទ្ធិទទួលបានសន្តិសុខសង្គម" ។ "**សន្តិសុខសង្គម**" ត្រូវបានផ្ដល់និយមន័យផ្សេងៗគ្នាទៅតាមការអនុវត្តរបស់ប្រទេស អង្គការ ឬស្ថាប័ននីមួយៗ យ៉ាងនេះក្ដី ពាក្យខាងលើនេះអាច

សង្កត់នូវចំណុចរួមមួយគឺ វិធានការណ៍ឱ្យសមាជិកសង្គមរស់នៅក្នុងបរិបទសមធម៌ និងសាមគ្គីធម៌សង្គម ដើម្បីការពារគ្នាទៅវិញទៅមកកុំឱ្យធ្លាក់ចូលស្ថានភាពក្រីក្រ ជួយទប់ទល់នឹងហានិភ័យសង្គម ធានាសន្តិសុខប្រាក់ចំណូល លើកកម្ពស់សុខុមាលភាព និងជីវភាពរស់នៅក្នុងភាពសមរម្យថ្លៃថ្នូរ។ របបសន្តិសុខសង្គមបានចាប់កំណើតនៅព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ ១៩៤០ ក្នុងទម្រង់ជាប្រព័ន្ធតាវកាលិកគ្រួសារ "**ហិបប្រាក់អន្តរវិជ្ជាជីវៈ**" ក្រោយពីព្រះរាជាណាចក្រកម្ពុជាទទួលបានឯករាជ្យពីអាណានិគមបារាំង "**ច្បាប់ស្តីពីការបង្កើតហិបប្រាក់អន្តរវិជ្ជាជីវៈសម្រាប់ទូទាត់វិភាជន៍គ្រួសារ**" ត្រូវបានប្រកាសឱ្យប្រើដោយក្រមលេខ៣ន.ស ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ ១៩៥៥ ស្របតាមច្បាប់នេះ "**ហិបប្រាក់អន្តរវិជ្ជាជីវៈសម្រាប់ទូទាត់វិភាជន៍គ្រួសារ**" ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ៣០៦ន.ស។ ជាអកុសល ព្រះរាជាណាចក្រកម្ពុជាបានធ្លាក់ចូលក្នុងវិនាសកម្មដ៏ខ្មៅងងឹងក្រោមរបបកម្ពុជាប្រជាធិបតេយ្យ (របបប្រល័យពូជសាសន៍ប៉ុល-ពត ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) ដែលបានធ្វើឱ្យរបបសន្តិសុខសង្គមត្រូវបានលុបបំបាត់ចោល និងបាននាំឱ្យប្រទេសធ្លាក់ដល់ក្រោមចំណុចសូន្យ។ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ របបសន្តិសុខសង្គមបានចាប់ផ្តើមមានជាថ្មីផ្នែកប្រាក់សោធនរបស់មន្ត្រីសាធារណៈ និងផ្នែកប្រាក់ប៉ះពាល់សុខភាពកម្មករនិយោជិតដែលធ្វើការនៅតាមរោងចក្រសហគ្រាសរដ្ឋ ដែលអនុវត្តដោយនាយកដ្ឋានបៀវត្សពលកម្មនៃក្រសួងផែនការ។ បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ នាយកដ្ឋានសន្តិសុខសង្គមត្រូវបានបង្កើតឡើងស្ថិតក្រោមក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន បន្ទាប់មកចាប់ពីឆ្នាំ២០០៥ បានស្ថិតក្រោមក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីទទួលបន្ទុកក្នុងការរៀបចំកិច្ចការគតិយុត្តសម្រាប់ការអនុវត្តរបបសន្តិសុខសង្គមដល់បុគ្គលដែលធ្វើការក្នុងវិស័យឯកជន។ ក្នុងឆ្នាំ២០០២ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវបានអនុម័តឱ្យប្រើប្រាស់យ៉ាងទូលំទូលាយដល់កម្មករនិយោជិត រហូតដល់ឆ្នាំ២០០៧ នាយកដ្ឋានសន្តិសុខសង្គមបានប្តូរមកជា **បេឡាជាតិរបបសន្តិសុខសង្គម** ដើម្បីទទួលបន្ទុកអនុវត្តច្បាប់ខាងលើឱ្យកាន់តែមានប្រសិទ្ធភាព។ ដោយទទួលបានជោគជ័យគួរជាទីមោទក ក្នុងការដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារក្នុងឆ្នាំ២០០៨ ទើបរាជរដ្ឋាភិបាលបានបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពក្នុងឆ្នាំ២០១៦ សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រកម្ពុជា ក្រោយអនុវត្តទទួលបានជោគជ័យលើវិស័យឯកជន រាជរដ្ឋាភិបាលបានផ្តល់សេចក្តីទុកចិត្តលើបេឡាជាតិសន្តិសុខសង្គម ដោយប្រគល់ភារកិច្ចបន្ថែមលើការអនុវត្តរបបសន្តិសុខសង្គមចំពោះបុគ្គលនៃវិស័យសាធារណៈ។ ការណ៍នេះជាកាលានុវត្តភាពឱ្យ **បេឡាជាតិរបបសន្តិសុខសង្គម** វិវឌ្ឍខ្លួនទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានឈ្មោះថា **បេឡាជាតិសន្តិសុខសង្គម** (ប.ស.ស.) និងជាប្រតិបត្តិករតែមួយគត់ដែលធ្វើប្រតិបត្តិការរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការងារ ដែលបង្កើតដោយព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០។

### ៣.១.២ បេសកកម្ម ទស្សនវិស័យ និងគោលដៅរបស់បេឡាជាតិសន្តិសុខសង្គម

- **បេសកកម្ម**

ផ្តល់សេវាផ្នែកសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងសង្គតិភាព សម្រាប់បុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញតិនៃច្បាប់ស្តីការងារដោយរួម

បញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ និងបុគ្គលស្វ័យនិយោជន៍ ដើម្បីធានាសន្តិសុខប្រាក់ចំណូល រួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ស្ថិរភាពសង្គម។

- **ទស្សនវិស័យ**

ជានាសន្តិសុខសង្គមប្រកបដោយសមធម៌ និងសាមគ្គីធម៌សង្គម ដើម្បីលើកកម្ពស់សុខុមាលភាព និងជីវភាពប្រជាពលរដ្ឋ។

- **គោលដៅបេឡាជាតិសន្តិសុខសង្គម**

-ពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ

-ពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

-ពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន

-សិក្សាសមិទ្ធិលទ្ធភាពដាក់ឲ្យដំណើរការរបបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារ

-រៀបចំ និងគ្រប់គ្រងរបបសន្តិសុខសង្គមយោងតាមបទប្បញ្ញត្តិនៃច្បាប់ដែលបានបង្កើតរបបសន្តិសុខសង្គមនេះសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

-ប្រមូលភាគទានពីសមាជិក និងនិយោជកទាំងអស់

-ជួយសម្រួល និងរៀបចំបទប្បញ្ញត្តិនៃសេវាសង្គម និងសុខភាពជូនសមាជិកទាំងអស់។

### ៣.១.៣ រចនាសម្ព័ន្ធរបស់បេឡាជាតិសន្តិសុខសង្គម



## ៣.២ លក្ខខណ្ឌ បែបបទ និងនីតិវិធីក្នុងការទទួលបានអត្ថប្រយោជន៍នៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គម

### ៣.២.១ លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងារ

#### ក. ការចុះបញ្ជីរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងហានិភ័យការងារ

❖ ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលស្ថិតនៅក្នុងដែនអនុវត្ត នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណា ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតកិច្ចមកចុះបញ្ជិកាសហគ្រាស គ្រឹស្ថានរបស់ខ្លួន នៅបេឡាជាតិសន្តិសុខសង្គម។ រយៈពេលកំណត់នៃការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន មានដូចតទៅ៖

- ចំពោះសហគ្រាសគ្រឹះស្ថាន ដែលកំពុងដំណើរការ និងមិនទាន់បានចុះបញ្ជិកានៅបេឡាជាតិសន្តិសុខសង្គម ត្រូវមានកាតកិច្ចមកចុះបញ្ជិកានៅបេឡាជាតិសន្តិសុខសង្គម រយៈពេលយ៉ាងយូរ ៣០ (សាមសិប)ថ្ងៃ បន្ទាប់បីប្រកាសនេះចូលជាធរមាន។
- ចំពោះសហគ្រាស គ្រឹះស្ថាន ដែលបើកដំណើរការថ្មី ក្រោយប្រកាសនេះចូលជាធរមានត្រូវមានកាតកិច្ចមកចុះបញ្ជិកានៅបេឡាជាតិសន្តិសុខសង្គម រយៈពេលយ៉ាងយូរ ៣០ (សាមសិប)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមបើកសហគ្រាស គ្រឹះស្ថាន។
- ចំពោះសហគ្រាស គ្រឹះស្ថាន ដែកបានចុះបញ្ជិកានៅបេឡាជាតិសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព រួចហើយ មិនមានកាតព្វកិច្ចក្នុងការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានឡើងវិញទេ។

ការចុះបញ្ជីសហគ្រាស ឬគ្រឹះស្ថានត្រូវធ្វើតាមទម្រង់"បញ្ជិកាសហគ្រាស គ្រឹះស្ថាន" ឬហៅថាទម្រង់ "១.០១" ដែលមានចែងក្នុងឧបសម្ព័ន្ធ ១ នៃប្រកាសនេះ។ និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវភ្ជាប់មកជាមួយទម្រង់ "១.០១" នូវវិញ្ញាបនបត្របញ្ជិកាពាណិជ្ជកម្មដែលចេញដោយក្រសួងពាណិជ្ជកម្ម ឬលិខិតតូបករណ៍គតិយុត្តសមមូលដទៃទៀត។

- និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះកម្មករនិយោជិតក្នុងពេលដំណាលគ្នានិងទម្រង់បញ្ជិកាសហគ្រាស គ្រឹះស្ថាន។
- និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវមានកាតព្វកិច្ចជូនដំណឹងមកបេឡាជាតិសន្តិសុខសង្គមក្នុងពេលយ៉ាងយូរ ៣០(សាមសិប)ថ្ងៃ បន្តាប់ពីមានការព្យួរ បិទ ឬ ផ្អាកសកម្មភាពអាជីវកម្ម ការប្តូរនិយោជក ឬម្ចាស់សហគ្រាស ឬអ្នកតំណាង អាសយដ្ឋាន ឬនាមករម៍សហគ្រាស។

❖ **ការចុះបញ្ជីកម្មករនិយោជិត**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវមានកាតកិច្ចចុះបញ្ជីកម្មករនិយោជិត មកក្នុងបេឡាជាតិសន្តិសុខសង្គម យ៉ាងយូររយៈពេល ៣ (បី) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទអនុញ្ញាតឱ្យចូលធ្វីការ លើកលែងតែកម្មករនិយោជិតដែលមានប័ណ្ណសមាជិកបេឡាជាតិសន្តិសុខសង្គមរួចហើយ។

នីតិវិធី និងបែបបទនៃការចុះបញ្ជីកម្មករនិយោជិត មកក្នុងបេឡាជាតិសន្តិសុខសង្គមត្រូវធ្វើតាមទម្រង់សាលាកប័ត្រព័ត៍មានកម្មករនិយោជិត ឬហៅថាទម្រង់ "១.០២" ដែលមានចែងក្នុងឧបសម្ព័ន២ នៃ

ប្រកាសនេះ។ ដើម្បីចុះបញ្ជីក្នុងបេឡាជាតិសន្តិសុខសង្គម កម្មករនោយោជិតសញ្ជាតិខ្មែរត្រូវមានអត្តសញ្ញាតប័ណ្ណសញ្ជាតិខ្មែរ ដោយឡែកចំពោះកម្មករនិយោជិតបរទេសត្រូវមានលិខិតឆ្លងដែន។

❖ **ការចុះបញ្ជីបុគ្គលស្វ័យនិយោជន៍**

ការចុះបញ្ជីសម្រាប់បុគ្គលស្វ័យនិយោជន៍ត្រូវធ្វើការកំណត់យោងអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ដូចខាងក្រោម៖

- សាមីខ្លួនត្រូវអញ្ជើញមកស្នើសុំធ្វើប័ណ្ណសមាជិកបេឡាជាតិសន្តិសុខសង្គមដោយផ្ទាល់
- ត្រូវមានអាយុមិនលើសពី៦០ ឆ្នាំគិតត្រឹមកាលបរិច្ឆេទស្នើសុំចុះបញ្ជី
- ភ្ជាប់ជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរច្បាប់ដើម(មានសុពលភាព)។

**ខ. លក្ខខណ្ឌនៃការទទួលបានសេវាប្រើប្រាស់នៅបេឡាជាតិសន្តិសុខសង្គម**

ដើម្បីទទួលបានការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងារគ្រប់សមាជិកទាំងអស់របស់បេឡាជាតិសន្តិសុខសង្គមត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

❖ **ផ្នែកថែទាំសុខភាព**

- សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ
  - បានចុះបញ្ជិការនៅបេឡាជាតិសន្តិសុខសង្គម
  - ការបង់ភាគទាន
- ប្រាក់បំណាច់ប្រចាំថ្ងៃព្យាបាលជំងឺ
  - បង់ភាគទានបាន២ខែជាប់គ្នា ឬបង់ភាគទានបាន៦ខែក្នុងកំឡុងរយៈពេល១២ខែគិតត្រឹមថ្ងៃមានបញ្ហាសុខភាព
  - អាក់ខានការងារចាប់ពីថ្ងៃទី៨ឡើង
  - ចូលប្រើប្រាស់សេវាព្យាបាលនៅមន្ទីរពេទ្យដៃគូបេឡាជាតិសន្តិសុខសង្គម
- ប្រាក់បំណាច់មាតុភាព
  - មានគ៌ភចាប់ពី២៦សប្តាហ៍ឡើង (សម្រាប់ឯកជន)
  - បង់ភាគទានបាន០៩ខែក្នុងអំឡុងពេល១២(ដប់ពីរ)ខែចុងក្រោយគិតរហូតមកទល់ខែដែលបានសម្រាលកូន(សម្រាប់ឯកជន)
  - មានគ៌ភចាប់ពី២៦សប្តាហ៍ឡើង(សម្រាប់បុគ្គលស្វ័យនិយោជន៍)
  - បង់ភាគទានបាន៩ខែក្នុងកំឡុង រយៈពេល១២ខែចុងក្រោយគិតរហូតមកទល់ខែបានសម្រាលកូន(សម្រាប់បុគ្គលស្វ័យនិយោជន៍) ។
- វិភាជន៍បូជាសព
  - ទទួលមរណភាពក្នុងកំឡុងរយះពេលបណ្ណសមាជិកបេឡាជាតិសន្តិសុខសង្គមនៅមានសុពលភាព (២លានពីបេឡាជាតិសន្តិសុខសង្គម) ។

❖ **ផ្នែកហានិភ័យការងារ**

- គ្រោះថ្នាក់កំឡុងពេលធ្វើដំណើរពីលំនៅស្ថានខ្លួនត្រង់ឆ្ពោះទៅកន្លែងធ្វើការ ឬវិលមកវិញដោយគ្មានឈប់ឬវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការងារ ដែលគេតម្រូវឱ្យទៅ

- គ្រោះថ្នាក់កំឡុងបំពេញការងារ
- ចេញពីកន្លែងការងារ(មុខរបរទាក់ទងជាតិពុល ឬតំបន់មិនប្រក្រតីដែលអាចនាំឱ្យកើតជម្ងឺផ្សេងៗ)
- ករណីគ្រោះថ្នាក់ហួតដល់បាតបង់ជីវិតកាតព្វ កិច្ចជូនដំណឹងនេះត្រូវផ្ទេរទៅសិទ្ធិវន្ត(បុគ្គលទទួលបានសិទ្ធិក្នុងការស្នើសុំតាវកាលិក) ។

**៣.២.២ ការបង់ភាគទានផ្នែកថែទាំសុខភាព និងហានិភ័យការងារ**

បុគ្គលនៃវិស័យសាធារណៈ និងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ការបង់ភាគទានសម្រាប់បុគ្គលនៃវិស័យសាធារណៈ និងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវធ្វើឡើងជាប្រចាំខែ ឬប្រចាំឆ្នាំដោយយកប្រាក់រៀលជាគោល និងយកអត្រាប្តូរប្រាក់មធ្យមប្រចាំខែដោយផ្អែកតាមអត្រាប្តូរប្រាក់ធនាគារជាតិនៃកម្ពុជាដែលជូនដំណឹងដោយបេឡាជាតិសន្តិសុខសង្គម។ កាតព្វកិច្ចបង់ភាគទាន ០,៨ ភាគរយសម្រាប់ផ្នែកហានិភ័យការងារ និង ២,៦ ភាគរយសម្រាប់ផ្នែកថែទាំសុខភាព និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវបង់ភាគទានមកបេឡាជាតិសន្តិសុខសង្គមយ៉ាងយូរបំផុតត្រឹម ថ្ងៃទី១៥ និងការដាក់ឯកសារយ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់។ ការមិនព្រមបង់ភាគទាន ឬការបង់ភាគទានក្រោយថ្ងៃទី៣០ ត្រូវចាត់ទុកជាការមិនបង់ភាគទាន។ ករណីនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានមិនបង់ភាគទានក្នុងរបបសន្តិសុខសង្គមនីមួយៗត្រូវទទួលការពិន័យអន្តរការណ៍ដូចមានកំណត់នៅក្នុងមាត្រា៩៨នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម។ ប្រាក់ឈ្នួលជាប់ភាគទានអប្បបរមាត្រូវកំណត់ស្មើនឹងចំនួន ៤០០ ០០០(បួនសែន)រៀល និងប្រាក់ឈ្នួលជាប់ភាគទានពិតានស្មើនឹងចំនួន១២០០០០០(មួយលានពីរសែន)រៀល។ ប្រាក់ឈ្នួលជាប់ភាគទាន គឺជាប្រាក់ឈ្នួលរបស់កម្មករនិយោជិតដែលតម្រូវឱ្យជាប់ភាគទានតាមច្បាប់ ឬប្រាក់ធនលាភរបស់កម្មករនិយោជិតដែលបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ចាប់ពី ២០ ភាគរយឡើងទៅឬប្រាក់សោធនរបស់កម្មករនិយោជិតដែលតម្រូវឱ្យជាប់ភាគទានផ្នែកថែទាំសុខភាព។ និយោជកដែលបង់ភាគទានប្រចាំឆ្នាំត្រូវមានកាតព្វកិច្ចផ្តល់របាយការណ៍តាមការកំណត់ដូចខាងក្រោម៖

- ករណីមិនមានចលនាចេញ ចូលបុគ្គលិករបស់ខ្លួនត្រូវរាយការណ៍រៀងរាល់១២ខែម្តង។
- ករណីមានចលនាចេញ ចូលបុគ្គលិករបស់ខ្លួន ត្រូវរាយការណ៍រៀងរាល់ ១៥ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃបម្រែបម្រួល។ របាយការណ៍អំពីចំនួនកម្មករនិយោជិត ត្រូវបញ្ជាក់អំពីចំនួនកម្មករនិយោជិតទាំងអស់ដែលមាននៅក្នុងខែដែលត្រូវរាយការណ៍ដោយត្រូវធ្វើតាមទម្រង់ "របាយការណ៍កម្មករនិយោជិត" ឬហៅថា E-Form។
- អ្នកក្នុងបន្ទុកសម្រាប់សមាជិកបេឡាជាតិសន្តិសុខសង្គមជាមន្ត្រីសាធារណៈភាគទាននៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព តាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលម្នាក់ៗដែលជាអ្នកក្នុងបន្ទុកសមាជិក បេឡាជាតិសន្តិសុខសង្គម ជាមន្ត្រីសាធារណៈ ត្រូវកំណត់ស្មើនឹង ១,៤ ភាគរយនៃប្រាក់ចំណូលជាប់ភាគទានរបស់សមាជិក បេឡាជាតិសន្តិសុខសង្គម ជាមន្ត្រីសាធារណៈ។ ប្រាក់ចំណូលជាប់ភាគទានត្រូវកំណត់ស្មើនឹង ៨៧០០០០ (ប្រាំបីរយចិតសិបពាន់)រៀល។ ភាគទាននៃរបបបេឡាជាតិសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់អ្នកក្នុងបន្ទុក

សមាជិក បេឡាជាតិសន្តិសុខសង្គម ជាមន្ត្រីសាធារណៈដែលជាបន្ទុករបស់សាមីជនត្រូវរ៉ាប់រងបង់ជំនួសដោយរាជរដ្ឋាភិបាលរហូតដល់មានការសម្រេចថ្មី។

- បុគ្គលស្វ័យនិយោជន៍ អ្នកក្នុងបន្ទុកសមាជិកបេឡាជាតិសន្តិសុខសង្គម ជាបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារនិងបុគ្គលស្វ័យនិយោជន៍ភាគទាននៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានស្ម័គ្រចិត្តសម្រាប់បុគ្គលម្នាក់ៗដែលជាអ្នកក្នុងបន្ទុកសមាជិកបេឡាជាតិសន្តិសុខសង្គមជាបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារនិងបុគ្គលស្វ័យនិយោជន៍ត្រូវកំណត់ស្មើនឹង ២,៦ ភាគរយនៃប្រាក់ចំណូលជាប់ភាគទានរបស់សាមីជន។ បុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិកបេឡាជាតិសន្តិសុខសង្គម ជាបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងបុគ្គលស្វ័យនិយោជន៍ អាចធ្វើការបង់ភាគទានដោយផ្ទាល់ ឬតាមរយៈប្រព័ន្ធនៃធនាគារដែលជាដៃគូរួមមាន៖

១. ធនាគារ អេស៊ីលីដា ភីអិលស៊ី (ACLEDA BANK PLC.)
២. ធនាគារ កាលណាឌីយ៉ា ក.អ (CANADIA BANK PLC.)
៣. ធនាគារ វីង (ខេមបូឌា)ម.ក ( WING BANK (CAMBODIA)PLC)
៤. ធនាគារ វឌ្ឍនៈអាស៊ីចំកាត់ ( ABA BANK)
៥. ក្រុមហ៊ុន លី ហួរ ផេ ប្រ៉ូ ភីអិលស៊ី ( លី ហួរ វេលុយ) (LY HOUR PAYPRO PLC.LY HOUR VELUY)
៦. ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ (JTRUST ROYAL BANK LTD.)
៧. ធនាគារ វឌ្ឍនៈ (VATTANAC BANK)
៨. ធនាគារ ពាណិជ្ជ ម.ក (PHNOM PENH COMMERCIAL BANK PLC )
៩. ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា ( FOREIGN TRADE BANK OF CAMBODIA )
១០. ធនាគារ អេស ប៊ី អាយ លី ហួរ ម.ក (SBI LY HOUR BANK PLC.)
១១. ធនាគារ ខេប៊ីប្រាសាក់ ម.ក (KB PRASAC BANK PLC.)។

## ៣.៣ អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គម

### ៣.៣.១ អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាថែទាំសុខភាព

#### ក. សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ

សមាជិកបេឡាជាតិសន្តិសុខសង្គមមានសិទ្ធិទទួលបានសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រដូចខាងក្រោម៖

១. ការផ្តល់សេវាព្យាបាលដោយសម្រាកក្នុងមូលដ្ឋានសុខាភិបាលដែលរួមមាន៖

- សេវាព្យាបាល និងថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងៗទៀត
- ឧបករណ៍ផ្នែកសល្យសាស្ត្រ និងសម្ភារបរិក្ខារផ្នែកវេជ្ជសាស្ត្រផ្សេងៗតាមតម្រូវការចាំបាច់សម្រាប់ការព្យាបាល
- ឱសថតាមវេជ្ជបញ្ជា
- បន្ទប់សម្រាកព្យាបាល។

២. ការផ្តល់សេវាពិគ្រោះជំងឺក្រៅដែលរួមមាន៖

- សេវាព្យាបាល និងថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងៗទៀត
- ឧបករណ៍ផ្នែកសល្យសាស្ត្រ និងសម្ភារបរិក្ខាផ្នែកវេជ្ជសាស្ត្រផ្សេងៗតាមតម្រូវការចាំបាច់សម្រាប់ការព្យាបាល
- ឱសថតាមវេជ្ជបញ្ជា។

៣. ការផ្តល់សេវាសម្រាលកូន សេវាព្យាបាលថែទាំមុននិងក្រោយសម្រាល។

៤. ការផ្តល់សេវាព្យាបាលដោយស្តំ ដោយចលនា ឬសេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រដទៃទៀត។

៥. ការផ្តល់សេវាសង្គ្រោះបន្ទាន់។ ក្នុងករណីសង្គ្រោះបន្ទាន់ សាមីជនរងគ្រោះ អាចទៅព្យាបាលនៅមូលដ្ឋានសុខាភិបាលដែលស្ថិតនៅជិតបំផុត។ ប្រសិន បើមូលដ្ឋានសុខាភិបាលនោះមិនមានកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមសាមីជនឬអ្នកតំណាងត្រូវជូនដំណឹងបន្ទាន់មកបេឡាជាតិសន្តិសុខសង្គម។

៦. ការផ្តល់សេវាបង្ការសុខភាព។

៧. ការផ្តល់សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះ និងសេវាបញ្ជូនសព។ ការផ្តល់សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះត្រូវផ្តល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់ និងដោយរថយន្តគិលានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាលតែប៉ុណ្ណោះ។ការផ្តល់សេវាបញ្ជូនអ្នកជំងឺធ្ងន់ធ្ងរមិនអាចព្យាបាលជា ឬសេវាបញ្ជូនសពត្រូវផ្តល់តាមតម្លៃរបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គម។

៨. សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ។ ការផ្តល់សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ សម្រាប់គាំទ្រដល់ការព្យាបាលនឹងថែទាំវេជ្ជសាស្ត្រ ឬសម្រាប់ជួយសម្រួលដល់អ្នកជំងឺ ឬជនរងគ្រោះក្នុងកំឡុងពេលសម្រាកព្យាបាល។

ចំពោះការប្រើប្រាស់សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រមានចែងក្នុងចំណុចទី១ ទី២ ទី៣ និងទី៤ ខាងលើត្រូវបានផ្តល់តែនៅក្នុងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមប៉ុណ្ណោះ។ ការប្រើប្រាស់សេវានៅមូលដ្ឋានសុខាភិបាលដទៃផ្សេងទៀតមិនត្រូវបានផ្តល់ជូនឡើយ លើកលែងតែករណីសង្គ្រោះបន្ទាន់។ សេវា ឬការព្យាបាលមួយចំនួនដែលមិនត្រូវបានរាប់បញ្ចូលក្នុងធានារ៉ាប់រងនេះរួមមាន៖

- ការព្យាបាលទាំងឡាយណាដែលមិនគិតថ្លៃដែលមានចែងក្នុងគោលនយោបាយសុខាភិបាលសាធារណៈ
- ការថែទាំធ្មេញ(ការសម្អាត ការប៉ះ និងការដាក់ធ្មេញ)
- ការព្យាបាល និងការវះកាត់ប្តូរភេទ
- ការផ្សាំ ឬប្តូរសិរីរាង្គផ្សេងៗ
- សេវាបង្កកំណើតដោយសិប្បនិម្មិត
- ការព្យាបាលដោយខ្លួនឯង
- ការព្យាបាល ឬការវះកាត់កែសម្ផស្ស
- ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត និងការព្យាបាលដោយកាមរស្មីឡាស៊ែ
- ការព្យាបាលញៀនសុរា និងផ្តាច់គ្រឿងញៀន
- ការព្យាបាលការអសមត្ថភាពផ្តល់កំណើត

- ការវះកាត់ដោយដាក់គ្រាប់ភ្នែកសប្បនិម្មិត
- ការវះកាត់បេះដូងនិងសរសៃឈាមបេះដូង
- ការលាងឈាម
- ការត្រួតពិនិត្យសុខភាពទូទៅ។

### ខ. ប្រាក់បំណាច់ប្រចាំថ្ងៃព្យាបាលជំងឺ

សមាជិក បេឡាជាតិសន្តិសុខសង្គមជាបុគ្គលទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ មានសិទ្ធិទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ លុះត្រាតែ៖

- បានចុះបញ្ជីផ្នែកថែទាំសុខភាព
- កំពុងបំពេញការងារនៅក្នុងសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីនៅបេឡាជាតិសន្តិសុខសង្គម
- បានបង់ភាគទាន២(ពីរ)ខែជាប់គ្នា ឬ៦(ប្រាំមួយ)ខែ ក្នុងរយៈពេល១២(ដប់ពីរ)ខែចុងក្រោយ គិតមកទល់ខែដែលមានជំងឺ ឬគ្រោះថ្នាក់ក្រៅពីហានិភ័យការងារ
- បានអាក់ខានការងារចាប់ពី៨ថ្ងៃឡើង ដោយសារការសម្រាកព្យាបាលថែទាំជំងឺ ឬបួសតាមវេជ្ជបញ្ជា នៅក្នុងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គម
-ប្រាក់បំណាច់ប្រចាំថ្ងៃត្រូវផ្តល់ដោយគិតពីថ្ងៃផ្អាកការងារដំបូង ដោយការចូលសម្រាកព្យាបាលជំងឺនៅតាមមូលដ្ឋានសុខាភិបាល។ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលនៅតាមមូលដ្ឋានសុខាភិបាលត្រូវកំណត់ស្មើនឹង៧០ ភាគរយនៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃដែលបានបង់ភាគទានសម្រាប់រយៈពេលជាក់ស្តែង មិនលើស៦ខែមុនខែដែលមានបញ្ហាសុខភាព។

❖ ប្រាក់បំណាច់នេះត្រូវផ្តល់ជូនតាមរូបមន្តដូចខាងក្រោម៖

**ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ= ៧០ភាគរយ× ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃដែលបានបង់ភាគទានរបស់សាមីជន × ចំនួនថ្ងៃឈប់សម្រាកព្យាបាល**

### គ. ប្រាក់បំណាច់មាតុភាព

សមាជិកបេឡាជាតិសន្តិសុខសង្គមលើកលែងបុគ្គលនៃវិស័យសាធារណៈ ដែលមានគភ៌ចាប់ពី២៦(ម្ភៃប្រាំមួយ)សប្តាហ៍ឡើងទៅមានសិទ្ធិទទួលបានប្រាក់បំណាច់មាតុភាព លុះត្រាតែ៖

- បានចុះបញ្ជីផ្នែកថែទាំសុខភាព
- បានបង់ភាគទានយ៉ាងតិច ៩(ប្រាំបួន)ខែក្នុងរយៈពេល១២(ដប់ពីរ)ខែចុងក្រោយ គិតមកទល់កាលបរិច្ឆេទសម្រាលកូន
- បានសម្រាលនៅតាមមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គម។

ករណីសមាជិកបេឡាជាតិសន្តិសុខសង្គមទៅសម្រាលកូននៅមូលដ្ឋានសុខាភិបាលដែលមិនបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមសាមីជនត្រូវទៅពិនិត្យសុខភាពក្រោយសម្រាលនៅមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមយ៉ាងយូរ ៤៥ ថ្ងៃគិត

ចាប់ពីថ្ងៃសម្រាល។ ប្រាក់បំណាច់ប្រចាំថ្ងៃ៧០ ភាគរយនៃប្រាក់ឈ្នួលមធ្យមជាប់ភាគទានប្រចាំថ្ងៃរបស់សាមីជនសម្រាប់រយៈពេល៩០(កៅសិប)ថ្ងៃនៃការឈប់សម្រាកមុន និងក្រោយសម្រាលកូន។

❖ ប្រាក់បំណាច់មាតុភាព ត្រូវផ្តល់ជូនតាមរូបមន្តដូចខាងក្រោម៖

**ប្រាក់បំណាច់មាតុភាព= ៧០ភាគរយ× ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃដែលបានបង់ភាគទានរបស់សាមីជន× ៩០ថ្ងៃ**

**ឃ. វិភាជន៍បូជាសព**

សមាជិកបេឡាជាតិសន្តិសុខសង្គម ជាបុគ្គលទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ដែលមានសុពលភាពប្រើប្រាស់សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ ហើយទទួលមរណភាពដោយសារគ្រោះថ្នាក់ ឬជំងឺក្រៅពីហានិភ័យការងារមានសិទ្ធិទទួលបានប្រាក់វិភាជន៍បូជាសពចំនួន ២ ០០០ ០០០(ពីរលាន)រៀល ពីបេឡាជាតិសន្តិសុខសង្គម។ សិទ្ធិវន្ត ឬអ្នកចាត់ចែងបូជាសព ត្រូវជូនដំណឹងមកបេឡាជាតិសន្តិសុខសង្គមរយៈពេលយ៉ាងយូរ ២(ពីរ)សប្តាហ៍ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលមរណភាពរបស់សមាជិកបេឡាជាតិសន្តិសុខសង្គម។

**ង. ដៃគូរសហការក្រសួងសុខាភិបាល**

❖ **មូលដ្ឋានសុខាភិបាលដៃគូ**

១. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងរាជធានីភ្នំពេញ
២. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តកំពង់ស្ពឺ
៣. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តកណ្តាល
៤. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តតាកែវ
៥. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តកំពង់ឆ្នាំង
៦. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តកំពង់ចាម
៧. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តត្បូងឃ្មុំ
៨. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តកំពង់ធំ
៩. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តព្រៃវែង
១០. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តស្វាយរៀង
១១. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តកំពត
១២. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តកែប
១៣. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តព្រះសីហនុ
១៤. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តកោះកុង
១៥. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តក្រចេះ
១៦. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តសៀមរាប
១៧. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តបាត់ដំបង
១៨. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តស្ទឹងត្រែង

១៩. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តបន្ទាយមានជ័យ

២០. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តប៉ៃលិន

២១. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តពោធិ៍សាត់

២២. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តរតនៈគីរី

២៣. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តមណ្ឌលគីរី

២៤. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តព្រះវិហារ

២៥. តារាងមូលដ្ឋានសុខាភិបាលដែលចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិសន្តិសុខសង្គមក្នុងខេត្តឧត្តរមានជ័យ។

**៣.៣.២ អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាធានារ៉ាប់រងហានិភ័យការងារ**

**ក. ការផ្តល់សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ**

សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រមានដូចខាងក្រោម៖

- ការព្យាបាល និងថែទាំមុខរបួស ឬជំងឺដែលបណ្តាលមកពីហានិភ័យការងារតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្ររហូតជាសះស្បើយទោះអ្នករងគ្រោះសម្រាក ឬមិនសម្រាកព្យាបាលនៅតាមមូលដ្ឋានសុខាភិបាលក្តី
- ការផ្តល់សេវាសង្គ្រោះបន្ទាន់
- ការផ្គត់ផ្គង់ឱសថសម្រាប់ការព្យាបាល និងសម្ភារៈប្រើប្រាស់បន្ទាប់បន្សំសម្រាប់ការព្យាបាល
- ការផ្តល់សេវាដឹកសព ឬសេវាបញ្ជូនជនរងគ្រោះដែលត្រូវសង្គ្រោះបន្ទាន់
- ការផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំអ្នករងគ្រោះក្នុងពេលសម្រាកព្យាបាលសម្រាប់ករណីធ្ងន់ធ្ងរដែលសាមីជនរងគ្រោះមិនអាចបម្រើខ្លួនឯងបាន។

**ខ. ប្រាក់បំណាច់សម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន**

តាវកាលិកនេះ សំដៅដល់ការអាក់ខានមិនអាចធ្វើការងារក្នុងរយៈពេលនៃការសម្រាកព្យាបាលជំងឺ ឬមុខរបួសដែលបណ្តាលមកពីហានិភ័យការងារដោយគិតរួមទាំងការសម្រាកក្រោយការព្យាបាលតាមវេជ្ជបញ្ជានៃគ្រូពេទ្យផ្លូវការដែលទទួលស្គាល់ដោយបេឡាជាតិសន្តិសុខសង្គម។ ចំពោះការអាក់ខាននេះ ជនរងគ្រោះនឹងទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ ដោយផ្តល់ជូនរាប់ចាប់ពីថ្ងៃទីពីរដែលសាមីជនរងគ្រោះថ្នាក់រហូតមុខរបួស ឬជំងឺជាសះស្បើយ ឬទទួលមរណភាពដោយគិតរួមទាំងរយៈពេលដែលគ្រូពេទ្យព្យាបាលអនុញ្ញាតឲ្យឈប់សម្រាកបន្ទាប់ពីចេញពីមូលដ្ឋានសុខាភិបាលផងដែរ។ ប្រាក់ឈ្នួលរបស់សាមីជនសម្រាប់ថ្ងៃផ្អាកការងារដំបូងជាបន្ទុករបស់និយោជក។ បុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារត្រូវទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ ៧០ភាគរយ នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់ខ្លួន។ ដោយឡែកចំពោះបុគ្គលនៃវិស័យសាធារណៈ ប្រាក់បៀវត្សរបស់សាមីជនរងគ្រោះត្រូវបានរក្សាទុកដដែល។ អាជ្ញាយុកាលនៃការស្នើសុំមានរយៈពេល ១ឆ្នាំ។

**គ. ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍**

សមាជិកបេឡាជាតិសន្តិសុខសង្គម ជាបុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ និងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវា

សមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះដែលទទួលរងហានិភ័យការងារបណ្តាលឲ្យបាត់បង់សមត្ថភាពការងារអចិន្រ្តៃយ៍ក្នុងកម្រិតចាប់ពី២០ភាគរយ ឡើង មានសិទ្ធិទទួលបានធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្រ្តៃយ៍។ សម្រាប់បុគ្គលដែលមានចែងក្នុងកថាខណ្ឌខាងលើដែលកំពុងទទួលបានធនលាភដោយការបាត់បង់សមត្ថភាពការងារអចិន្រ្តៃយ៍ដោយផ្នែក ប៉ុន្តែបានទទួលរងហានិភ័យការងារជាថ្មីត្រូវទទួលបានធនលាភស្របតាមកម្រិតនៃការបាត់បង់សមត្ថភាពការងារសរុប។ ដោយកម្រិតនៃការបាត់បង់សមត្ថភាពការងារសរុបនេះត្រូវស្មើនឹងកម្រិតបាត់បង់សមត្ថភាពការងារដើមដំបូងបូកនឹងកម្រិតបាត់បង់សមត្ថភាពការងារបន្តបន្ទាប់នៃសរីរាង្គផ្សេងទៀតប៉ុន្តែមិនត្រូវលើសពី១០០ ភាគរយឡើយ។ ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្រ្តៃយ៍ត្រូវចាត់ទុកជាប្រាក់បណ្តោះអាសន្នជានិច្ច និងត្រូវត្រួតពិនិត្យឡើងវិញជារៀងរាល់ឆ្នាំដោយអនុលោមតាមអត្រាអតិផរណាដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បេឡាជាតិសន្តិសុខសង្គមនឹងរៀបចំឱ្យមានការពិនិត្យសុខភាព និងវាយតម្លៃកម្រិតបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះជាទៀងទាត់ដើម្បីវិនិច្ឆ័យពីការប្រែប្រួលចំពោះកម្រិតនៃការបាត់បង់សមត្ថភាពការងារ និងមានការវាយតម្លៃព្រមទាំងសើរើចំនួនប្រាក់ធនលាភដែលត្រូវផ្តល់ឡើងវិញ។ ករណីសាមីជនរងគ្រោះជំទាស់ ឬមិនបានចូលខ្លួនមកពិនិត្យតាមការកំណត់ខាងលើបេឡាជាតិសន្តិសុខសង្គមអាចផ្អាកការផ្តល់ធនលាភរហូតដល់មានការបង្ហាញខ្លួនរបស់សាមីជន។ អាជ្ញាយុកាលនៃការស្នើសុំប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្រ្តៃយ៍មានរយៈពេល ៥ឆ្នាំ។

- ការគណនាប្រាក់ធនលាភបាត់បង់សមត្ថភាពការងារអចិន្រ្តៃយ៍ត្រូវគិតតាមរូបមន្តដូចខាងក្រោម៖

**ធនលាភបាត់បង់សមត្ថភាពការងារអចិន្រ្តៃយ៍= ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃx ( កម្រិតបាត់បង់សមត្ថភាពការងារ–១/៥កម្រិតបាត់បង់សមត្ថភាពការងារ )**

### ឃ. វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្រ្តៃយ៍

សមាជិកបេឡាជាតិសន្តិសុខសង្គម ជាបុគ្គលនៃវិស័យសាធារណៈ និងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ដែលទទួលរងហានិភ័យការងារបណ្តាលឲ្យបាត់បង់សមត្ថភាពការងារអចិន្រ្តៃយ៍ ក្នុងកម្រិតតិចជាង ២០ ភាគរយពិការភាព ឬខូចខាតផ្នែកណាមួយនៃរាងកាយ) មានសិទ្ធិទទួលបានវិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្រ្តៃយ៍។ អាជ្ញាយុកាលនៃការស្នើសុំមានរយៈពេល ១ឆ្នាំ។ វិភាជន៍ សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្រ្តៃយ៍ត្រូវបានបើកផ្តល់ជូនជនរងគ្រោះតែម្តងគត់ ដោយគិតតាមរូបមន្តដូចខាងក្រោម៖

**វិភាជន៍បាត់បង់សមត្ថភាពការងារអចិន្រ្តៃយ៍= ប្រាក់បៀវត្សមូលដ្ឋានប្រចាំខែរបស់មន្ត្រីសាធារណៈ ឬ ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ x កម្រិតបាត់បង់សមត្ថភាពការងារ x ២០ ភាគរយមេគុណតម្លៃបច្ចុប្បន្ន**

### ង. វិភាជន៍បូជាសព និងធនលាភឧត្តរជីវី

សមាជិកបេឡាជាតិសន្តិសុខសង្គមដែលទទួលរងហានិភ័យការងាររហូតដល់បាត់បង់ជីវិតបេឡាជាតិសន្តិសុខសង្គមផ្តល់វិភាជន៍បូជាសព និងធនលាភឧត្តរជីវី។

**វិភាជន៍បូជាសព** សំដៅដល់ប្រាក់ឧបត្ថម្ភសម្រាប់ការចាត់ចែងបូជាសពសមាជិកបេឡាជាតិសន្តិសុខសង្គមដែលទទួលរងហានិភ័យការងាររហូតដល់បាត់បង់ជីវិត។ វិភាជន៍បូជាសពសម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ និងបុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារដោយរួមបញ្ចូលទាំង

បុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះចំនួន ១០ ០០០ ០០០ (ដប់លាន)រៀល ដោយត្រូវផ្ដល់ជូនសិទ្ធិវន្តដែលស្ថិតនៅក្នុងបន្ទុកផ្ទាល់នៃជនរងគ្រោះ ឬអ្នករៀបចំចាត់ចែងបូជាសព។ លក្ខខណ្ឌដើម្បីទទួលបានវិភាជន៍បូជាសព សិទ្ធិវន្តត្រូវបំពេញទម្រង់ទាមទារវិភាជន៍បូជាសពក្នុងកំឡុងពេល ៣ខែ បន្ទាប់ពីការទទួលមរណភាពរបស់សមាជិកបេឡាជាតិសន្តិសុខសង្គម។ សិទ្ធិនៃការទាមទារវិភាជន៍បូជាសពនេះមានសុពលភាពរយៈពេល ១ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលមរណភាពរបស់សមាជិកបេឡាជាតិសន្តិសុខសង្គម។

**ធនលាភឧត្តរជីវី** សំដៅដល់ប្រាក់ឧបត្ថម្ភដែលត្រូវបើកផ្ដល់ដល់សិទ្ធិវន្តឧត្តរជីវីរបស់សមាជិក បេឡាជាតិសន្តិសុខសង្គមដែលទទួលរងហានិភ័យការងាររហូតបាត់បង់ជីវិត។ សិទ្ធិវន្តនៃធនលាភឧត្តរជីវី រួមមាន សហព័ទ្ធ និងកូន ព្រមទាំងឪពុកម្ដាយឬមនុស្សចាស់ជរាដែលរស់នៅក្នុងបន្ទុកផ្ទាល់របស់សាមីជន មុនពេលទទួលមរណភាព និងត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. សម្រាប់ប្ដីឬប្រពន្ធ ត្រូវចុះសំបុត្រអាពាហ៍ពិពាហ៍មុនកាលបរិច្ឆេទនៃហានិភ័យការងារ ឬមុនពេលទទួលមរណៈភាពដោយហានិភ័យការងារ។

២. ចំពោះកូន ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មិនទាន់រៀបអាពាហ៍ពិពាហ៍
- ជាកូនបង្កើត
- ក្នុងករណីមានការលែងលះឬករណីមរណៈភាពនៃប្ដីឬប្រពន្ធ កូននៃគូស្រករក្រោយ ដែលនៅក្នុងបន្ទុកផ្ទាល់របស់សាមីជន ក៏មានសិទ្ធិដូចកូននៃអាពាហ៍ពិពាហ៍មុនដែរ
- កូនសុំរបស់សាមីជនរងគ្រោះ ដែលបានសុំស្របតាមបទប្បញ្ញត្តិជាធរមាន ឬក្មេង កំព្រារស់នៅក្នុងបន្ទុកផ្ទាល់របស់សាមីជនរងគ្រោះ
- មានអាយុមិនលើសពី២១(ម្ភៃមួយ)ឆ្នាំ។

កូនពិការ ឬមានជំងឺរ៉ាំរ៉ៃហើយមិនអាចប្រកបការងារឬមុខរបរដែលមានប្រាក់ចំណូលត្រូវផ្ដល់ធនលាភឧត្តរជីវីអស់មួយជីវិត។ ការកំណត់ស្ថានភាពពិការឬជំងឺរ៉ាំរ៉ៃត្រូវបញ្ជាក់ដោយគ្រូពេទ្យឯកទេស និងមានការយល់ព្រមពីក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃបេឡាជាតិសន្តិសុខសង្គម។

៣.ឪពុកម្ដាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុកផ្ទាល់របស់ជនរងគ្រោះដែលមានអាយុយ៉ាងតិច៦០(ហុកសិប) ឆ្នាំ គិតត្រឹមកាលបរិច្ឆេទនៃការទទួលមរណភាពរបស់ជនរងគ្រោះនិងមិនមានប្រកបមុខរបរដែលមានប្រាក់ចំណូល ឬប្រាក់សោធននិវត្តន៍ ឬសោធនជរាភាព។ ចំពោះឪពុកម្ដាយឬមនុស្សចាស់ជរាដែលមានជំងឺរ៉ាំរ៉ៃព្យាបាល មិនជា ឬមានទុព្វលភាព និងមិនមាន ប្រាក់ចំណូល ឬប្រាក់សោធននិវត្តន៍ ឬសោធនជរាភាព មិនត្រូវបានកំណត់អាយុឡើយ។

៤.សិទ្ធិទទួលបានធនលាភឧត្តរជីវីត្រូវផុតរលត់ក្នុងករណីដូចខាងក្រោម៖

- សាមីជនទទួលមរណៈភាព
- ប្ដីឬប្រពន្ធរៀបអាពាហ៍ពិពាហ៍ជាថ្មី ស្របតាមនីតិវិធីច្បាប់ដែលមានជាធរមាន។ ក្នុងករណីនេះ សាមីជនត្រូវជូនដំណឹងមកបេឡាជាតិសន្តិសុខសង្គម យ៉ាងយូរ ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការរៀបអាពាហ៍ពិពាហ៍ថ្មី។

- សិទ្ធិនៃការទាមទារធនលាភឧត្តរជីវីត្រូវអស់សុពលភាពត្រឹមរយៈពេល ៥ឆ្នាំ។

ធនលាភឧត្តរជីវី សម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ ត្រូវបានផ្ដល់ជូនតាមរូបមន្តដូចខាងក្រោម៖

**ក. ចំពោះសិទ្ធិវន្ត ជារួមមានប្ដី ឬប្រពន្ធ កូន និងឪពុកម្ដាយ ឬមនុស្សចាស់នៅក្នុងបន្ទុក៖**

- ប្ដី ឬប្រពន្ធ = ៣/៥ x ៦៣ ភាគរយប្រាក់បៀវត្សមូលដ្ឋានប្រចាំខែរបស់សាមីជន
- ធនលាភសរុបសម្រាប់កូន = ២/៥ x ៦៣ ភាគរយប្រាក់បៀវត្សមូលដ្ឋានប្រចាំខែរបស់សាមីជន
- ធនលាភសរុបសម្រាប់ឪពុកម្ដាយ ឬមនុស្សចាស់ដែលនៅក្នុងបន្ទុក = ៧ ភាគរយប្រាក់បៀវត្សមូលដ្ឋានប្រចាំខែរបស់សាមីជន

**ខ. ចំពោះសិទ្ធិវន្ត ជារួមមាន ប្ដី ឬប្រពន្ធ និងកូន៖**

-ប្ដី ឬប្រពន្ធ = ៣/៥ x ៧០ ភាគរយប្រាក់បៀវត្សមូលដ្ឋានប្រចាំខែរបស់សាមីជន

- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ x ៧០ ភាគរយប្រាក់បៀវត្សមូលដ្ឋានប្រចាំខែរបស់សាមីជន

**គ. ចំពោះសិទ្ធិវន្ត ជារួមមាន ប្ដី ឬប្រពន្ធ និងឪពុកម្ដាយឬមនុស្សចាស់៖**

- ប្ដី ឬប្រពន្ធ = ២៨ មូលដ្ឋានប្រចាំខែរបស់សាមីជន
- ធនលាភសរុបសម្រាប់ឪពុកម្ដាយ ឬមនុស្សចាស់ដែលនៅក្នុងបន្ទុក = ២៨ ភាគរយប្រាក់បៀវត្សមូលដ្ឋានប្រចាំខែរបស់សាមីជន

**ឃ. ចំពោះសិទ្ធិវន្តជា ប្ដី ឬប្រពន្ធ ឬកូននៅក្នុងបន្ទុក ធនលាភសម្រាប់ប្ដី ឬប្រពន្ធ ឬធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ៥៦ ភាគរយប្រាក់បៀវត្សមូលដ្ឋានប្រចាំខែរបស់សាមីជន**

**ង. ចំពោះសិទ្ធិវន្តជា ឪពុកម្ដាយឬមនុស្សចាស់ ធនលាភសម្រាប់ឪពុកម្ដាយ ឬមនុស្សចាស់ដែលនៅក្នុងបន្ទុក= ៣៥ ភាគរយប្រាក់បៀវត្សមូលដ្ឋានប្រចាំខែរបស់សាមីជន**

**ច. ចំពោះសិទ្ធិវន្តជារួមមាន កូន និងឪពុកម្ដាយឬមនុស្សចាស់៖**

- ធនលាភសរុបសម្រាប់កូន = ២៨ ភាគរយប្រាក់បៀវត្សមូលដ្ឋានប្រចាំខែរបស់សាមីជនធនលាភសរុបសម្រាប់ឪពុកម្ដាយ ឬមនុស្សចាស់ដែលនៅក្នុងបន្ទុក = ២៨ ភាគរយប្រាក់បៀវត្សមូលដ្ឋានប្រចាំខែរបស់សាមីជន។

ធនលាភឧត្តរជីវី សម្រាប់បុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវផ្ដល់ឱ្យសិទ្ធិវន្តនៃជនរងគ្រោះតាមអត្រាដូចខាងក្រោម៖

**ក. ក្នុងករណីសិទ្ធិវន្ត មានរួមទាំងប្រពន្ធ ឬប្ដី កូន និងឪពុកម្ដាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក**

- ប្រពន្ធ ឬប្ដី= ៣/៥ x ៦៣ ភាគរយប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ x ៦៣ ភាគរយប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ
- ធនលាភសរុបសម្រាប់ឪពុកម្ដាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ៧ ភាគរយប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ

**ខ. ក្នុងករណីសិទ្ធិវន្តមានតែប្រពន្ធ ឬប្ដី និង/ឬកូន**

- ប្រពន្ធ ឬប្ដី= ៣/៥ x ៧០ ភាគរយប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ x ៧០ ភាគរយប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ

**គ. ក្នុងករណីសិទ្ធិវន្ត មានតែឪពុកម្ដាយ ឬមនុស្សចាស់ជរា**

- ធនលាភសរុបសម្រាប់ឪពុកម្ដាយឬមនុស្សចាស់ជរាក្នុងបន្ទុក = ៣៥ ភាគរយប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ

**ឃ. ក្នុងករណីសិទ្ធិវន្ត មានតែកូន និងឪពុកម្ដាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក**

- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២៨ ភាគរយប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ
- ធនលាភសរុបសម្រាប់ឪពុកម្ដាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨ ភាគរយប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ

**ង. ក្នុងករណីសិទ្ធិវន្ត មានតែ ប្រពន្ធ ឬប្ដី និងឪពុកម្ដាយ ឬមនុស្សចាស់ជរា**

- ប្រពន្ធ ឬប្ដី = ២៨ ភាគរយប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ
- ធនលាភសរុបសម្រាប់ឪពុកម្ដាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨ ភាគរយប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ

**ច. ក្នុងករណីសិទ្ធិវន្តមានតែប្រពន្ធ ឬប្ដី ឬកូនក្នុងបន្ទុក = ៥៦%ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ**

**ច. សេវាស្តារនីតិសម្បទា**

សមាជិកបេឡាជាតិសន្តិសុខសង្គម ជាបុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ និងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ដែលទទួលរងហានិភ័យបណ្ដាលឲ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍មានសិទ្ធិទទួលបានសេវាស្តារនីតិសម្បទាដែលរួមមាន សេវាស្តារនីតិសម្បទាផ្នែកវេជ្ជ-សាស្ត្រ ឬសេវាបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ ឬសេវាសង្គម។

លក្ខខណ្ឌដើម្បីទទួលបានសេវាស្តារនីតិសម្បទា ត្រូវធ្វើឡើងតាមរយៈទម្រង់ "ពាក្យស្នើសុំសេវា ស្តារនីតិសម្បទា" ដោយមានភ្ជាប់មកជាមួយនូវវេជ្ជបញ្ជារបស់គ្រូពេទ្យ ឬអ្នកឯកទេសដែលទទួលស្គាល់ដោយបេឡាជាតិសន្តិសុខសង្គម ឬឯកសារពាក់ព័ន្ធចាំបាច់ដទៃទៀត។ ជនពិការត្រូវមកបង្ហាញខ្លួននៅបេឡាជាតិសន្តិសុខសង្គមដើម្បីពិនិត្យ វាយតម្លៃ និងតម្រង់ទិសការផ្តល់សេវា។ ក្នុងករណីដែលជនពិការ មិនអាចបង្ហាញខ្លួនក្នុងការស្នើសុំដោយសារស្ថានភាពពិការភាពមានសភាពធ្ងន់ធ្ងរ ការស្នើសុំនេះ អាចត្រូវធ្វើឡើងដោយអ្នកតំណាង។ អ្នកតំណាងអាចជាសហព័ន្ធ កូន ឬជនដែលមានភារៈថែរក្សាដោយផ្ទាល់ចំពោះជនពិការ។

- **សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ** ត្រូវបានផ្តល់ជូនសមាជិក បេឡាជាតិសន្តិសុខសង្គមដែលទទួលរងហានិភ័យ ការងារ សម្រាប់គាំទ្រដល់ការព្យាបាល និងថែទាំវេជ្ជសាស្ត្រឬសម្រាប់ជួយសម្រួលដល់ជនរងគ្រោះ ដែលបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍។
- **សេវាបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ** ត្រូវបានផ្តល់ជូនសមាជិក បេឡាជាតិសន្តិសុខសង្គមដែលធ្លាក់ខ្លួនពិការដោយហានិភ័យការងារ ដើម្បីមានឱកាសទទួលបានការងារឬមុខរបរថ្មី ស្របតាមកាយសម្បទារបស់ ខ្លួន។ ដើម្បីទទួលបានសេវាបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ ជនពិការត្រូវមានលក្ខខណ្ឌកាយសម្បទា និងសតិបញ្ញាសមស្រប។ ការបណ្តុះបណ្តាលនេះ ត្រូវបានផ្តល់ជូនរយៈពេលយ៉ាងយូរ ១ឆ្នាំ។
- **សេវាសង្គម** ត្រូវបានផ្តល់ជូនសមាជិក បេឡាជាតិសន្តិសុខសង្គមដែលទទួលរងហានិភ័យការងារបណ្តាលឱ្យពិការភាពមានសិទ្ធិទទួលបាននូវសេវាដូចជា ការប្រឹក្សា ការតម្រង់ទិស ការអប់រំចិត្តសាស្ត្រ និងសេវា សង្គមនានា ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវផ្នែកចិត្តសាស្ត្រសង្គម ទទួលបានភាពម្ចាស់ការស្របតាមស្ថានភាពរស់នៅប្រចាំថ្ងៃ។

# ជំពូកទី៤
# ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

## ៤.១ ការវិភាគលើចំណុចខ្លាំងរបស់បេឡាជាតិសន្តិសុខសង្គម

បេឡាជាតិសន្តិសុខសង្គមបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់ប្រជាពលរដ្ឋ និងសង្គម រួមទាំងបានជួយលើកស្ទួយទៅលើវិស័យសុខាភិបាលកម្ពុជាឱ្យកាន់តែមានការរីកចម្រើនផងដែល។ ហើយខាងក្រោមនេះជាចំណុចខ្លាំងរបស់បេឡាជាតិសន្តិសុខសង្គម៖

- បេឡាជាតិសន្តិសុខសង្គមមានគោលការណ៍ និងនីតិវិធីច្បាស់លាស់ក្នុងការរៀបចំទម្រង់បែបបទនៃការចុះបញ្ជិកាសហគ្រាស ម្ចាស់សហគ្រាស កម្មករនិយោជិត និងបុគ្គលសាធារណៈដើម្បីបំពេញបែបបទនៅក្នុងបេឡាជាតិសន្តិសុខសង្គម
- ផ្តល់សេវាផ្នែកសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងសង្គតិភាព សម្រាប់បុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈ និងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- ធានាសន្តិសុខសង្គមប្រកបដោយសមធម៌ និងសាមគ្គីធម៌សង្គមដើម្បីលើកកម្ពស់សុខុមាលភាព និងជីវភាពរបស់ប្រជាពលរដ្ឋ
- ដើម្បីធានាសន្តិសុខប្រាក់ចំណូល រួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ស្ថិរភាពសង្គម
- សម្រាប់សហគ្រាសងាយស្រួលប្រកាស និងបង់ប្រាក់ក្នុងប្រពន្ធ័បង់ប្រាក់បេឡាជាតិសន្តិសុខសង្គម។
- ចំពោះបុគ្គលស្វ័យនិយោជន៍ងាយស្រួលក្នុងការបង់ប្រាក់តាមរយៈកម្មវិធីទូរសព្ទដៃជាមួយធនាគារដែលជាដៃគូរបស់បេឡាជាតិសន្តិសុខសង្គម។
- បេឡាជាតិសន្តិសុខសង្គមបានធ្វើការពង្រីកសាខាបានទាំង ២៥ ខេត្តក្រុងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ៤.២ ការវិភាគលើចំណុចខ្សោយខរបស់បេឡាជាតិសន្តិសុខសង្គម

ការប្រើប្រាស់សេវាថែទាំសុខភាពនៅបេឡាជាតិសន្តិសុខសង្គមពិតជាល្អណាស់ដល់សមាជិក ប៉ុន្តែក៏មានចំណុចខ្វះខាតមួយចំនួនដែលកើតមាននៅពេលសមាជិកទៅទទួលការប្រើប្រាស់សេវាថែទាំសុខភាពផងដែល។ ហើយខាងក្រោមនេះជាចំណុចខ្សោយរបស់បេឡាជាតិសន្តិសុខសង្គម៖

- នៅតាមមន្ទីពេទ្យមួយចំនួន ដែលជាដៃគូបេឡាជាតិសន្តិសុខសង្គមមានភាពយឺតយ៉ាវ មិនយកចិត្តទុកដាក់ក្នុងការផ្តល់សេវាជូនសមាជិកបេឡាជាតិសន្តិសុខសង្គម
- នៅតាមមន្ទីពេទ្យមួយចំនួន ដែលជាដៃគូបេឡាជាតិសន្តិសុខសង្គម មានភាពខ្វះខាតនូវបរិក្ខារវេជ្ជសាស្ត្រសម្រាប់ព្យាបាល
- តាមមន្ទីរពេទ្យខ្លះមានបុគ្គលិកមួយចំនួនប្រើពាក្យសម្តី ឬកាយវិការមិនសមរម្យទៅកាន់សមាជិកនៅពេលដែលទៅទទួលសេវាប្រើប្រាស់តាមមន្ទីរដែលជាដៃគូបេឡាជាតិសន្តិសុខសង្គម
- សមាជិកបេឡាជាតិសន្តិសុខសង្គមអាចជួបការលំបាកនៅពេលហៅទៅកាន់លេខ(១២៨៦/១២៩៧) ដើម្បីដោះស្រាយបញ្ហា ឬការសុំព័ត៌មានដោយមានការឆ្លើយតបយឺតយ៉ាវ
- ការផ្តល់សេវា ឬការព្យាបាលជំងឺមួយចំនួនមិនរាប់បញ្ចូលក្នុងធានារ៉ាប់រង របស់បេឡាជាតិសន្តិសុខសង្គម។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

ការប្រើប្រាស់សេវាថែទាំសុខភាព និងហានិភ័យការងាររបស់បេឡាជាតិសន្តិសុខសង្គមបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់សមាជិក និងសហគមន៍ទាំងមូល។ ការលើកកម្ពស់សុខភាពរបស់ប្រជាពលរដ្ឋតាមរយៈសេវាពិនិត្យសុខភាព វ៉ាក់សាំង និងការព្យាបាលជំងឺប្រចាំកាយ។ ម្យ៉ាងវិញទៀតសេវានេះអាចជួយកាត់បន្ថយការចំណាយសុខភាពរបស់គ្រួសារក្រីក្រដោយផ្តល់សេវាឥតគិតថ្លៃ ឬក៏ថ្លៃសមរម្យ។ លើសពីនេះបានជួយពង្រឹងស្មារតីសុខុមាលភាព និងអាយុជីវិតរបស់ប្រជាជន ដោយមានការគាំទ្រពីមន្ត្រីជំនាញផ្ទាល់។

ទោះបីមានអត្ថប្រយោជន៍ជាច្រើន ក៏សេវាថែទាំសុខភាពនេះក៏មានហានិភ័យ និងកង្វះខាតដែរ។ ឧទាហរណ៍ ការខ្វះខាតធនធានសំខាន់ ដូចជាគ្រូពេទ្យ ថ្នាំ ឬបរិក្ខារវេជ្ជសាស្ត្រ អាចបណ្តាលឱ្យការបម្រើសេវាមានភាពយឺតយ៉ាវក្នុងការព្យាបាលអ្នកជំងឺ។ បន្ថែមពីនេះ ការគ្រប់គ្រងខ្វះប្រសិទ្ធភាព ឬអសមត្ថភាព ធ្វើឱ្យមានភាពមិនស្មើគ្នាក្នុងការទទួលបានសេវាថែទាំសុខភាព ក្នុងការផ្តល់សេវានៅតាមតំបន់នានា ដែលស្ថិតនៅក្នុងប្រទេសកម្ពុជា។

ដើម្បីធានាប្រសិទ្ធភាពនៃសេវាថែទាំសុខភាពនិងហានិភ័យការងារ គួរមានការពង្រឹងសមត្ថភាពមន្ត្រីបុគ្គលិកនានា ការបញ្ចូលធនធានឱ្យបានគ្រប់គ្រាន់ និងការគ្រប់គ្រងតាមដានយ៉ាងម៉ឺងម៉ាត់។ ក្រៅពីនេះ ការធ្វើយុទ្ធនាការផ្សព្វផ្សាយអំពីសេវាទៅកាន់សហគមន៍ ជាពិសេសក្នុងតំបន់ដែលងាយរងគ្រោះ នឹងជួយឱ្យប្រជាពលរដ្ឋទទួលបានអត្ថប្រយោជន៍ពេញលេញ។ នាពេលអនាគត ការផ្តល់សេវាថែទាំសុខភាពនិងហានិភ័យការងារ របស់បេឡាជាតិសន្តិសុខសង្គមមានជឿនលឿន ក្នុងការផ្តល់សុខសុវត្ថិភាព ជូនដល់ប្រជាពលរដ្ឋ ឱ្យមានទំនុកចិត្តក្នុងការទទួលអត្ថប្រយោជន៍ថែទាំសុខភាព និងហានិភ័យការងារ របស់បេឡាជាតិសន្តិសុខសង្គមកាន់តែប្រសើរឡើង។

## ៥.២ ការផ្តល់អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើការប្រើប្រាស់សេវាថែទាំសុខភាព និងការស្វែងយល់ពីអត្ថប្រយោជន៍នៅពេលចូលជាសមាជិកបេឡាជាតិសន្តិសុខសង្គមរួចមក យើងយល់ឃើញថាបេឡាជាតិសន្តិសុខសង្គមពិតជាបានផ្តល់ភាពងាយស្រួលនៅពេលដែលសមាជិកបានទទួលការប្រើប្រាស់សេវាថែទាំសុខភាពរបស់បេឡាជាតិសន្តិសុខសង្គម ប៉ុន្តែក៏មានចំណុចខ្វះខាតមួយចំនួនផងដែលនៅពេលដែលសមាជិកទៅទទួលការប្រើប្រាស់សេវាថែទាំសុខភាព ដែលត្រូវធ្វើការកែតម្រូវឡើងវិញ។ ដូច្នេះ ក្រុមនាងខ្ញុំសូមធ្វើការផ្តល់អនុសាសន៍មួយចំនួនដូចខាងក្រោម៖

-បេឡាជាតិសន្តិសុខសង្គមគួរតែមានការចាត់វិធានការណ៍ក្នុងការកែសម្រួល ក៏ដូចជាផ្តល់ការអប់រំដល់គ្រប់ស្ថានប័ន មន្ទីរពេទ្យ ដែលជាដៃគូសហការជាមួយបេឡាជាតិសន្តិសុខសង្គមដែលពាក់ពន្ធ័ក្នុងការផ្តល់នូវសេវាប្រើប្រាស់ជូនដល់ប្រជាពលរដ្ឋ ដើម្បីទទួលបានអត្ថប្រយោជន៍ឱ្យបានគ្រប់ៗគ្នា និងសិទ្ធិស្មើៗគ្នា

-បង្កើតយន្តការត្រួតពិនិត្យគុណភាពសេវាប្រើប្រាស់នៅតាមមន្ទីរពេទ្យដៃគូទាំងអស់

-ធ្វើឱ្យប្រព័ន្ធហៅទូរស័ព្ទ (១២៨៦/១២៩៧) កាន់តែមានប្រសិទ្ធភាព និងឆ្លើយតបយ៉ាងរហ័ស

-បង្កើតយន្តការតាមដាន និងវាយតម្លៃប្រសិទ្ធភាពសេវាប្រើប្រាស់ជាប្រចាំ។

# ឯកសារយោង

# ឯកសារយោង

- **ឯកសារយោងជាភាសាខ្មែរ**


អនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការ បង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅ ក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។ អាចរកបាននៅ http://www.nssf.gov.kh (បេឡាជាតិសន្តិសុខសង្គម)

ទីផ្សារ (17/October/2019)

http://khsearch.com


- **ឯកសារយោងជាភាសាបរទេស**


National Social Security Fund
http://www.nssf.gov.kh
World Health Organization (WHO). (1948/April/07)
https://www.who.int
Florence Nightingale (1859) Notes on Nursing. What It Is and What It Is Not
https://www.nationalarchives.gov.uk
American Nurses Association (ANA) (2015). Nursing Scope and Standards of Practice
https://www.nursingworld.org
Dorothea Orem (1971) Nursing. Concepts of Practice
https://nurseslabs.com
International Council of Nurses (ICN) (2021). ICN Definition of Nursing
http://www.icn.ch

Ebers Papyrus (1875). The Papyrus Ebers ទំព័រទី១-១១០

https://en.m.wikipedai.org

Hippocratic Corpus (1525). The Genuine Works of Hippocrates ទំព័រទី១-៥០

https://en.m.wikipedai.org

The Canon of Medicine (1473). Avicenna´s Medicine ទំព័រ ១-១០០០

https://en.m.wikipedia.org

De Materia Medica (1478).Google Books: De Materia Medica ទំព័រ ១-៥០០

https://books.google.com.kh

Florence Nightingale (1859). Notes on Nursing: What It Is and What It Is Not ទំព័រ ១-100

https://books.google.com.kh

Constitution of the World Health Organization(07/April/1948). Worl Health Assembly ទំព័រ ១-២០

https://www.who.int

World Health Organization (WHO) reports on COVID-19 vaccines (2020-2021 ) ទំព័រ ១៥០

https://www.who.int
The National Archives(02/April/2003). Public Records Ac
https://www.nationalarchives.gov.uk
Paul Martin RN (2012-2014). Nurseslabs
https://nurseslabs.com
Davi Bourget and David Chalmers (2009). Philpapers
https://philpapers.org
Nurseslabs (12/May/2014) Wayback Machine (Internet Archive)
https://nurseslabs.com
Dr. Sauul McLeod (2007) SimplyPsychology
https://www.simplypsychology.org

American Psychological Association, APA (1994) APA PsycNet
https://psycnet.apa.org
Scientific Research. Becker (1974 )
https://www.scrip.org
Nurseslabs. Dorothea Orem (1971)
https://nurseslabs.com
Nurseslabs. Betty Neuman (1972)
https://nurseslabs.com
Nation Social Security Fud(01/January/2024) ផ្នែកហានិភ័យការងារ
https://www.nssf.gov.kh
OSHA. Occupational Safety and Health Theory (29/December/1970)
https://www.osha.gov
Videos Learning (12/June/2023)
https://videoslearning.com
An Introduction to the principles of Morals and Legislation (5/February/2018)
https://www.econlib.org
Utilitarianism(book) (1861)
https://en.wikipedia.org

- **ឯកសារយោងជាគេហទំព័រ**

គេហទំព័រ http://www.nssf.gov.kh (ចូលទស្សនាថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០២៥)
គេហទំព័រ http://www.nssf.gov.kh (ចូលទស្សនាថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://www.nationalarchives.gov.uk (ចូលទស្សនាថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://www.nursingworld.org (ចូលទស្សនាថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://nurseslabs.com (ចូលទស្សនាថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ http://www.icn.ch (ចូលទស្សនាថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://en.m.wikipedai.org (ចូលទស្សនាថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://en.m.wikipedai.org (ចូលទស្សនាថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://en.m.wikipedia.org (ចូលទស្សនាថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://books.google.com.kh (ចូលទស្សនាថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://books.google.com.kh (ចូលទស្សនាថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://www.who.int (ចូលទស្សនាថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://www.who.int (ចូលទស្សនាថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://www.nationalarchives.gov.uk (ចូលទស្សនាថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://nurseslabs.com (ចូលទស្សនាថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://philpapers.org (ចូលទស្សនាថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://nurseslabs.com (ចូលទស្សនាថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://www.simplypsychology.org (ចូលទស្សនាថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://psycnet.apa.org (ចូលទស្សនាថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០២៥)

គេហទំព័រ https://www.scrip.org (ចូលទស្សនាថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://nurseslabs.com (ចូលទស្សនាថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://nurseslabs.com (ចូលទស្សនាថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://www.nssf.gov.kh (ចូលទស្សនាថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://www.osha.gov (ចូលទស្សនាថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://videoslearning.com (ចូលទស្សនាថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ http://khsearch.com (ចូលទស្សនាថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://www.econlib.org (ចូលទស្សនាថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០២៥)
គេហទំព័រ https://en.wikipedia.org (ចូលទស្សនាថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០២៥)

# ឧបសម្ព័ន

# ឧបសម្ព័ន

# ព្រះរាជក្រម

នស/រកម/១១១៩/ ០១៨

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីរបបសន្តិសុខសង្គម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ច្បាប់

## ស្ដីពី

# របបសន្តិសុខសង្គម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

### មាត្រា១ .- គោលបំណង

ច្បាប់នេះមានគោលបំណងបង្កើតឲ្យមានរបបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាឲ្យមានសមធម៌និងសាមគ្គីធម៌សង្គម និងដើម្បីលើកកម្ពស់សុខុមាលភាពនិងជីវភាពរបស់ប្រជាពលរដ្ឋ។

### មាត្រា២ .- គោលដៅ

ច្បាប់នេះមានគោលដៅកំណត់អំពីគោលការណ៍ទូទៅ បែបបទ យន្តការអនុវត្ត និងប្រព័ន្ធគ្រប់គ្រងរបបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមានផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការងារ។

### មាត្រា៣ .- វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះបុគ្គលទាំងអស់ដូចខាងក្រោម៖

១. បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈរួមមាន៖

- មន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដែលបម្រើការងារនៅតាមក្រសួង ស្ថាប័ន អង្គភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- មន្ត្រីរាជការដែលស្ថិតនៅក្រោមច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ លើកលែងផ្នែកប្រាក់សោធន
- មន្ត្រីរាជការដែលបម្រើការងារនៅក្នុងស្ថាប័នតុលាការ
- មន្ត្រីនគរបាលជាតិនិងមន្ត្រីពន្ធនាគារ ចំពោះតែតាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រក្នុងផ្នែកថែទាំសុខភាព
- មន្ត្រីដែលបម្រើការងារនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- មន្ត្រីរាជការដែលបម្រើការងារនៅក្នុងអាជ្ញាធរសវនកម្មជាតិ
- អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន
- មន្ត្រីជាប់កិច្ចសន្យាដែលបម្រើការនៅតាមក្រសួង ស្ថាប័ន អង្គភាព នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមានការទទួលស្គាល់ដោយក្រសួងមុខងារសាធារណៈ
- បុគ្គលនៃវិស័យសាធារណៈផ្សេងទៀត ដែលត្រូវកំណត់ដោយអនុក្រឹត្យ។

២. បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ។

៣. បុគ្គលស្វ័យនិយោជន៍។

ច្បាប់នេះមិនមានវិសាលភាពអនុវត្តលើយោធិននៃកងយោធពលខេមរភូមិន្ទ ដែលមានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៤ .. និយមន័យ**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះមានកំណត់និយមន័យដូចមានចែងនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២
## គោលការណ៍ទូទៅនៃរបបសន្តិសុខសង្គម

**មាត្រា៥ .. ផ្នែកប្រាក់សោធន**

របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលនៃវិស័យសាធារណៈ ត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលរដ្ឋនិងបុគ្គលនៃវិស័យសាធារណៈមានកាតព្វកិច្ចរួមគ្នាក្នុងការបង់ភាគទាន។

របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលនិយោជកនិងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ មានកាតព្វកិច្ចរួមគ្នាក្នុងការបង់ភាគទាន។

របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលស្វ័យនិយោជន៍ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦ .. ផ្នែកថែទាំសុខភាព**

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ ត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលរដ្ឋ បុគ្គលនៃវិស័យសាធារណៈ អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន មានកាតព្វកិច្ចរួមគ្នាក្នុងការបង់ភាគទាន។

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលនិយោជកនិងបុគ្គលទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ មានកាតព្វកិច្ចរួមគ្នាក្នុងការបង់ភាគទាន។

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់បុគ្គលស្វ័យនិយោជន៍ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៧ .. ផ្នែកហានិភ័យការងារ**

របបសន្តិសុខសង្គម ផ្នែកហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលរដ្ឋត្រូវមានកាតព្វកិច្ចក្នុងការបង់ភាគទានផ្នែកនេះ។

របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវា

សមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ចដែលនិយោជក ត្រូវមានកាតព្វកិច្ចក្នុងការបង់ភាគទានផ្នែកនេះ។

**មាត្រា៨ .- ផ្នែកនិកម្មភាពការងារ**

របបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារត្រូវមានលក្ខណៈជារបបភាគទានជាកាតព្វកិច្ច ដែលនិយោជកនិងកម្មករនិយោជិតត្រូវមានកាតព្វកិច្ចរួមគ្នាក្នុងការបង់ភាគទានផ្នែកនេះ។

**មាត្រា៩ .- ចំណែកនៃភាគទានសម្រាប់របបភាគទានជាកាតព្វកិច្ច**

ចំណែកនៃភាគទានរបស់បុគ្គលនៃវិស័យសាធារណៈនិងបុគ្គលទាំងឡាយដែលស្ថិត នៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះសម្រាប់របបភាគទានជាកាតព្វកិច្ច ក្នុងផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព និងនិកម្មភាពការងារមិនត្រូវលើសពី៥០%(ហាសិបភាគរយ)នៃ ភាគទានសរុបឡើយ។

ប្រាក់ឈ្នួលឬប្រាក់បៀវត្សជាប់ភាគទានត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៣
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា១០ .- ក្រុមប្រឹក្សាជាតិគាំពារសង្គម**

រាល់ប្រតិបត្តិការសន្តិសុខសង្គមត្រូវស្ថិតនៅក្រោមការសម្របសម្រួល តាមដាន និង តម្រង់ទិសក្នុងកម្រិតគោលនយោបាយនិងយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គមត្រូវកំណត់ដោយ ព្រះរាជក្រឹត្យ។

**មាត្រា១១ .- និយ័តករសន្តិសុខសង្គម**

ត្រូវបានបង្កើតនិយ័តករសន្តិសុខសង្គមដែលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

១. កំណត់បទប្បញ្ញត្តិប្រុងប្រយ័ត្ន ស្តង់ដារប្រតិបត្តិការ វិធានចាំបាច់នានា និងគោល ការណ៍ណែនាំស្តីពីវិនិយោគមូលនិធិសន្តិសុខសង្គម។

២. តាមដានស្ថានភាពហិរញ្ញវត្ថុរបស់ស្ថាប័នប្រតិបត្តិករសន្តិសុខសង្គម។

៣. បង្កើតយន្តការការពារសមាជិកនិងផ្សះផ្សាវិវាទនៅពេលមានទំនាស់។

៤. ត្រួតពិនិត្យអនុលោមភាព ដើម្បីធានាថាប្រតិបត្តិការនៅក្នុងការផ្តល់សេវាសន្តិសុខ សង្គមប្រព្រឹត្តទៅដោយតម្លាភាព គណនេយ្យភាព និងចីរភាពហិរញ្ញវត្ថុ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់និយ័តករសន្តិសុខសង្គមត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១២ .- បេឡាជាតិសន្តិសុខសង្គម**

បេឡាជាតិសន្តិសុខសង្គមដែលសរសេរជាអក្សរកាត់ថា **ប.ស.ស**. ជាស្ថាប័នប្រតិបត្តិករ តែមួយគត់ដែលធ្វើប្រតិបត្តិការរបបសន្តិសុខសង្គម ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ។

**ប.ស.ស**. ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលត្រូវបង្កើតដោយព្រះរាជក្រឹត្យ ស្ថិត ក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម និងស្ថិត ក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៣.- ភារកិច្ចរបស់បេឡាជាតិសន្តិសុខសង្គម**

**ប.ស.ស.** មានភារកិច្ចដូចខាងក្រោម៖

១. គ្រប់គ្រងនិងចាត់ចែងផ្នែកទាំងអស់នៃរបបសន្តិសុខសង្គមដែលកំណត់ដោយច្បាប់នេះ។

២. ធានាផ្តល់តាវកាលិកសន្តិសុខសង្គមសម្រាប់សមាជិក **ប.ស.ស.** ក្នុងគោលដៅជួយសម្រាលការលំបាកក្នុងជីវភាពនៅពេលជួបប្រទះហានិភ័យជាយថាហេតុនានាជាអាទិ៍ ជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ និកម្មភាពការងារ មាតុភាព ជំងឺ ឬគ្រោះថ្នាក់ ព្រមទាំងយថាភាពដទៃផ្សេងទៀត។

៣. ប្រមូលនិងគ្រប់គ្រងភាគទានរបបសន្តិសុខសង្គមនៃផ្នែកនីមួយៗព្រមទាំងប្រភពចំណូលដទៃផ្សេងទៀត។

៤. ចុះបញ្ជីនិងគ្រប់គ្រងលេខសម្គាល់សមាជិក **ប.ស.ស.**។

៥. ត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិនៃច្បាប់នេះ ដោយសហគ្រាស គ្រឹះស្ថាន ឬអង្គភាពពាក់ព័ន្ធដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ **ប.ស.ស.**។

៦. អប់រំ ផ្សព្វផ្សាយ និងត្រួតពិនិត្យការអនុវត្តវិធានការបង្ការហានិភ័យការងារ និងបង្ការសុខភាពសម្រាប់សមាជិក **ប.ស.ស.**។

៧. សិក្សា ស្រាវជ្រាវ និងអង្កេតហានិភ័យការងារ។

៨. សិក្សា ស្រាវជ្រាវ និងរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការកំណត់ប្រភេទជំងឺវិជ្ជាជីវៈ។

៩. ចុះកិច្ចព្រមព្រៀងនិងត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាល។

១០. សិក្សា វិភាគ និងវាយតម្លៃហិរញ្ញវត្ថុលើផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម។

១១. អនុវត្តសកម្មភាពពាក់ព័ន្ធនឹងសុខភាពនិងសង្គម ដែលពាក់ព័ន្ធនឹងអត្ថប្រយោជន៍នៃសមាជិក **ប.ស.ស.**។

១២. ចាត់ចែងនិងគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម។

**មាត្រា១៤.- ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម**

**ប.ស.ស.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម | ប្រធាន |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | សមាជិក |
| - តំណាងក្រសួងមុខងារសាធារណៈ១រូប | សមាជិក |
| - តំណាងក្រសួងសុខាភិបាល១រូប | សមាជិក |
| - តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា១រូប | សមាជិក |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី១រូប | សមាជិក |
| - តំណាងនិយោជក២រូប | សមាជិក |
| - តំណាងសមាជិក **ប.ស.ស.** ២រូប | សមាជិក |
| - អគ្គនាយក **ប.ស.ស.** | សមាជិកអចិន្ត្រៃយ៍។ |

**មាត្រា១៥ .- អង្គភាពប្រតិបត្តិនៃបេឡាជាតិសន្តិសុខសង្គម**

**ប.ស.ស**. ត្រូវចាត់ចែង គ្រប់គ្រងការងារប្រចាំថ្ងៃដោយអគ្គនាយក១(មួយ)រូបដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ និងអគ្គនាយករងមួយចំនួនជាជំនួយការ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ **ប.ស.ស**. ដែលមានកំណត់ក្នុងច្បាប់នេះ ជាសមត្ថកិច្ចរបស់អធិការសន្តិសុខសង្គម។ ការតែងតាំងនិងតួនាទីភារកិច្ចរបស់អធិការសន្តិសុខសង្គម ត្រូវកំណត់ដោយអនុក្រឹត្យ។

បុគ្គលិករបស់ **ប.ស.ស**. ជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដែលត្រូវបានផ្ទេរឬជ្រើសរើសថ្មីតាមសំណើរបស់អគ្គនាយកនៃ **ប.ស.ស**. និងបុគ្គលិកជាប់កិច្ចសន្យាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុងនិងលក្ខន្តិកៈបុគ្គលិកនៃ **ប.ស.ស**. ស្របតាមច្បាប់ស្តីពីការងារ។

**មាត្រា១៦ .- ការគ្រប់គ្រងមូលនិធិសន្តិសុខសង្គម**

ការគ្រប់គ្រងមូលនិធិរបស់ផ្នែកនីមួយៗនៃរបបសន្តិសុខសង្គមត្រូវស្ថិតនៅក្រោមក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃ **ប.ស.ស**.។ ក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃ **ប.ស.ស**. ត្រូវរៀបចំគោលការណ៍នៃការគ្រប់គ្រងមូលនិធិ ការគ្រប់គ្រងការវិនិយោគ ផែនការវិនិយោគ និងកញ្ចប់វិនិយោគដាក់ជូនក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**. ពិនិត្យនិងអនុម័តដោយអនុលោមតាមគោលការណ៍ណែនាំស្តីពីការវិនិយោគរបស់និយ័តករសន្តិសុខសង្គម ដើម្បីស្នើសុំការសម្រេចចុងក្រោយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងការបំពេញតួនាទីរបស់ខ្លួន ក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃ **ប.ស.ស**. ត្រូវធ្វើរបាយការណ៍ស្តីពីការរក្សានិងការគ្រប់គ្រងមូលនិធិសន្តិសុខសង្គមគ្រប់ផ្នែកជូនក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**. និយ័តករសន្តិសុខសង្គម និងអគ្គនាយកនៃ **ប.ស.ស**. ជាទៀងទាត់។

សមាសភាព គុណវុឌ្ឍិ ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គម ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៤
## របបសន្តិសុខសង្គមផ្នែកប្រាក់សោធន
### ផ្នែកទី១
### គោលការណ៍រួម

**មាត្រា១៧ .- បុគ្គលត្រូវគាំពារ**

បុគ្គលដែលត្រូវគាំពារក្នុងផ្នែកប្រាក់សោធនមានដូចខាងក្រោម៖

១. បុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈ។

២. បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ។

៣. បុគ្គលស្វ័យនិយោជន៍។

**មាត្រា១៨ ._ តាវកាលិកផ្នែកប្រាក់សោធន**

តាវកាលិកផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច រួមមាន សោធនជរាភាព សោធនទុព្វលភាព សោធនឧត្តរជីវី និងវិភាជន៍បូជាសព។

តាវកាលិកផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៩ ._ ភាគទានផ្នែកប្រាក់សោធន**

អត្រាភាគទានផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាសនិងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ ត្រូវកំណត់ដោយអនុក្រឹត្យ។

អត្រាភាគទានផ្នែកប្រាក់សោធនសម្រាប់បុគ្គលស្វ័យនិយោជន៍ត្រូវកំណត់ដោយអនុក្រឹត្យ។

អត្រាភាគទានផ្នែកប្រាក់សោធនត្រូវដំឡើងតាមវិធីសាស្ត្របុព្វលាភជណ្ដើរឬវិធីសាស្ត្រសមស្របមួយដែលអនុម័តដោយក្រុមប្រឹក្សាជាតិគាំពារសង្គម។

**មាត្រា២០ ._ សិទ្ធិវន្តនៃសោធនឧត្តរជីវី**

សិទ្ធិវន្តនៃសោធនឧត្តរជីវី រួមមាន សហព័ទ្ធនិងកូននៅក្នុងបន្ទុកផ្ទាល់របស់សាមីជនដែលត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១. មិនមានប្រកបការងារឬមុខរបរមានប្រាក់ចំណូលលើបន្ទាត់នៃភាពក្រីក្រ។

២. ចំពោះសហព័ទ្ធ ត្រូវចុះសំបុត្រអាពាហ៍ពិពាហ៍មុនកាលបរិច្ឆេទដែលសាមីជនធ្លាក់ខ្លួនឈឺឬគ្រោះថ្នាក់ជាយថាហេតុ ដែលបណ្ដាលឲ្យទទួលមរណភាព។

៣. ចំពោះកូន ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មិនទាន់រៀបអាពាហ៍ពិពាហ៍
- មានអាយុមិនលើសពី១៨(ដប់ប្រាំបី)ឆ្នាំ

កូនពិការឬមានជំងឺរ៉ាំរ៉ៃ ហើយមិនអាចប្រកបការងារឬមុខរបរដែលមានប្រាក់ចំណូលត្រូវផ្តល់សោធនឧត្តរជីវីអស់មួយជីវិត។ ការកំណត់ស្ថានភាពពិការឬជំងឺរ៉ាំរ៉ៃត្រូវបញ្ជាក់ដោយគ្រូពេទ្យឯកទេស និងមានការយល់ព្រមពីក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ**ប.ស.ស.**។ ក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ **ប.ស.ស.** អាចវាយតម្លៃឡើងវិញលើស្ថានភាពពិការឬជំងឺរ៉ាំរ៉ៃ ក្នុងករណីចាំបាច់។

សិទ្ធិទទួលបានសោធនឧត្តរជីវីត្រូវផុតរលត់ក្នុងករណីដូចខាងក្រោម៖

- សិទ្ធិវន្តទទួលមរណភាព
- សហព័ទ្ធរៀបអាពាហ៍ពិពាហ៍ជាថ្មីស្របតាមនីតិវិធីច្បាប់ដែលមានជាធរមាន។ ក្នុងករណីនេះ សាមីជនត្រូវជូនដំណឹងមក **ប.ស.ស.**យ៉ាងយូរ៣០(សាមសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការរៀបអាពាហ៍ពិពាហ៍ថ្មី។

**មាត្រា២១ ._ ប្រភពធនធានផ្នែកប្រាក់សោធន**

ធនធានផ្នែកប្រាក់សោធនមានប្រភពមកពី៖

- ការបង់ភាគទានពីរដ្ឋ និយោជក និងសមាជិក **ប.ស.ស.**
- ផលដែលបានមកពីការវិនិយោគ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ១៦៨/២២ ក.ប/ប្រ.ក.ប.ស.ស

# ប្រកាស
# ស្តីពី
# បែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងការបង់ភាគទាន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងបេឡាជាតិសន្តិសុខសង្គម

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ១៤០ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៧នៃអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម ០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព តាមច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅបង្កើតយន្តការផ្តល់ជូនសមាជិក ប.ស.ស នូវសេវាបង្ការសុខភាព និងតាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជំងឺ ឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ព្រមទាំងសហព័ទ្ធ និងកូនដែលស្ថិតនៅក្នុងបន្ទុកផ្ទាល់នៃកម្មករនិយោជិតដែលជាសមាជិក ប.ស.ស និងសមាជិក ប.ស.ស ដែលកំពុងទទួលបានប្រាក់ធនលាភ ដោយការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ និងឧត្តរជីវី។

**មាត្រា ៤.-**

វាក្យសព្ទបច្ចេកទេសដែលប្រើនៅក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

- **ថែទាំសុខភាព** សំដៅដល់ការធានារ៉ាប់រងសុខភាពសង្គម ដែលត្រូវផ្តល់តាវកាលិក សេវាបង្ការសុខភាព តាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជំងឺ ឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។
- **តាវកាលិក** សំដៅដល់ការផ្តល់សេវាបង្ការសុខភាព សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃនៅពេលសម្រាកព្យាបាលជំងឺឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងមាតុភាព។
- **សហព័ទ្ធ** សំដៅដល់ ប្រពន្ធ ឬប្តី ដែលនៅមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់។
- **ឧត្តរជីវី** សំដៅដល់អ្នកនៅរស់មានជីវិត ជាប្រពន្ធ ឬ ប្តី និងកូន នៅក្នុងបន្ទុកផ្ទាល់នៃសាមីជនដែលជាសមាជិកប.ស.ស ក្រោយពីទទួលមរណភាពដោយហានិភ័យការងារ។

## ជំពូកទី ២

## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា ៥.-**

បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) គឺជាស្ថាប័នប្រតិបត្តិករតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**មាត្រា ៦.-**

ក្រុមប្រឹក្សាជាន់ខ្ពស់មួយ ដែលជាបញ្ញត្តិករប្រព័ន្ធសន្តិសុខសង្គម ត្រូវបង្កើតឡើងដោយអនុក្រឹត្យដោយឡែក ដើម្បីគ្រប់គ្រងធ្វើអធិការកិច្ច តាមដាន ត្រួតពិនិត្យរាល់ការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពរបស់ ប.ស.ស និងកំណត់គោលនយោបាយអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម។

## ជំពូកទី ៣

## ភាគទាន តាវកាលិក និងប្រាក់ត្រៀមបម្រុងផ្នែកថែទាំសុខភាព

### ផ្នែកទី ១

### ភាគទានផ្នែកថែទាំសុខភាព

**មាត្រា ៧.-**

និយោជក និងកម្មករនិយោជិត ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចបង់ភាគទានផ្នែកថែទាំសុខភាពជូនដល់ ប.ស.ស ។ ផ្នែកនៃភាគទានដែលជាបន្ទុករបស់កម្មករនិយោជិត មិនត្រូវលើសពីផ្នែកនៃភាគទានដែលជាបន្ទុករបស់និយោជកឡើយ។

អត្រាភាគទានផ្នែកថែទាំសុខភាព របបបទ និងនីតិវិធីនៃការបង់ភាគទាននេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

### ផ្នែកទី ២

### តាវកាលិកផ្នែកថែទាំសុខភាព

**មាត្រា ៨.-**

តាវកាលិកផ្នែកថែទាំសុខភាព ដែលកំណត់ក្នុងអនុក្រឹត្យនេះរួមមាន ការផ្តល់សេវាបង្ការសុខភាព ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជំងឺ ឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។

ប្រភេទសេវា និងជំងឺដែលមិនទាន់ត្រូវបានដាក់បញ្ចូលក្នុងតាវកាលិកផ្នែកថែទាំសុខភាព ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើពីក្រុមប្រឹក្សាភិបាល នៃប.ស.ស។

របបបទ និងនីតិវិធី នៃការផ្តល់តាវកាលិកផ្នែកថែទាំសុខភាព ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

យន្តការនៃការទូទាត់ចំណាយសេវាបង្ការសុខភាព ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

**មាត្រា ៩.-**

ការទទួលបានតាវកាលិកថែទាំសុខភាព ត្រូវអនុលោមតាមលក្ខខណ្ឌដែលពាក់ព័ន្ធនឹងរយៈពេលជាប់រ៉ង និងរយៈពេលយោង ដែលលក្ខខណ្ឌទាំងនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

## ផ្នែកទី ៣
## ប្រាក់បម្រុងផ្នែកថែទាំសុខភាព

**មាត្រា ១០.-**

ប្រាក់ត្រៀមបម្រុងអប្បបរមាផ្នែកថែទាំសុខភាព ត្រូវស្មើនឹងចំនួនទឹកប្រាក់ដែលបានចំណាយសម្រាប់តាវកាលិក ក្នុងអំឡុងពេល ០១ (មួយ) ឆ្នាំចុងក្រោយ ។

## ជំពូកទី ៤
## ការទទួលស្គាល់ និងការត្រួតពិនិត្យគុណភាព
## សេវារបស់មូលដ្ឋានសុខាភិបាល
## ផ្នែកទី ១
## ការទទួលស្គាល់គុណភាពសេវា

**មាត្រា ១១.-**

ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវផ្តល់ដោយមូលដ្ឋានសុខាភិបាល ដែលមានការទទួលស្គាល់ពីក្រសួងសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ។

ការទទួលស្គាល់គុណភាពសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវអនុវត្តស្របតាមគោលការណ៍ដែលកំណត់ដោយក្រសួងសុខាភិបាល។

## ផ្នែកទី ២
## ការត្រួតពិនិត្យគុណភាពសេវា

**មាត្រា ១២.-**

គុណភាពសេវារបស់មូលដ្ឋានសុខាភិបាល ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ តាមដាន និងឃ្លាំមើលរបស់គណៈកម្មការវេជ្ជសាស្ត្រ នៃប.ស.ស។

សមាសភាព និងតួនាទីភារកិច្ចរបស់គណៈកម្មការវេជ្ជសាស្ត្រ នៃប.ស.ស ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

## ជំពូកទី ៥
## ដំណាក់កាលនៃការអនុវត្ត

**មាត្រា ១៣.-**

ដំណាក់កាលដំបូង ការផ្តល់សេវាថែទាំសុខភាពត្រូវអនុវត្តចំពោះតែសមាជិក ប.ស.ស និងឧត្តរជីវី។

ការផ្តល់សេវាថែទាំសុខភាពចំពោះសហព័ទ្ធ និងកូន ដែលនៅក្នុងបន្ទុកផ្ទាល់របស់សាមីជន ត្រូវអនុវត្តជាបន្តបន្ទាប់អនុលោមតាមស្ថានភាព សង្គម សេដ្ឋកិច្ចជាក់ស្តែង ដែលត្រូវកំណត់ដោយប្រកាសក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងនាយកបេឡាជាតិរបបសន្តិសុខសង្គម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
សូមហត្ថលេខា

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# តារាងការលិកផ្នែកថែទាំសុខភាព

**សម្រាប់មន្ត្រីប.ស.ស.**

លេខតារាការលិក [ ][ ][ ][ ][ ] / [ ][ ]

ហត្ថលេខា ......./......./.......

❶ នាមករណ៍សហគ្រាស-ស្ថាប័ន៖........................................................................................................

លេខអត្តសញ្ញាណសហគ្រាស-ស្ថាប័ន៖ [ ][ ][ ][ ][ ][ ][ ][ ] លេខទូរស័ព្ទ៖ [ ][ ][ ][ ][ ][ ][ ][ ][ ][ ]

❷ គោត្តនាមនិងនាមសមាជិកប.ស.ស. ........................................................................................................

លេខអត្តសញ្ញាណសមាជិកប.ស.ស. ៖ [ ][ ][ ][ ][ ][ ][ ][ ][ ][ ][ ][ ][ ][ ][ ][ ]

អាសយដ្ឋានផ្លូវលេខ.................សង្កាត់(ឃុំ)..............................ខណ្ឌ(ស្រុក)..........................រាជធានី(ខេត្ត) ..........................

លេខទូរស័ព្ទ៖ [ ][ ][ ][ ][ ][ ][ ][ ][ ][ ] អ៊ីម៉ែលE-Mail: ..........................................................................

❸ ឈ្មោះមន្ទីរពេទ្យ៖ ........................................................................................................

អាសយដ្ឋានផ្លូវលេខ..............សង្កាត់(ឃុំ)........................ខណ្ឌ(ស្រុក)............................រាជធានី(ខេត្ត) ...............................

ប្រភេទគ្រោះថ្នាក់ឬជំងឺ៖ ........................................................................................................

ចំនួនថ្ងៃសម្រាកព្យាបាល៖ ............ថ្ងៃ ចាប់ពីថ្ងៃខែឆ្នាំ............/.........../.......... ដល់ថ្ងៃខែឆ្នាំ.........../.........../............

❹ ការទាមទារផ្នែកថែទាំសុខភាព

- [ ] ផ្នែកសង្គ្រោះបន្ទាន់
- [ ] ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលសម្រាកព្យាបាលជំងឺ
- [ ] ប្រាក់បំណាច់មាតុភាព
- [ ] វិភាជន៍បូជាសព
- [ ] ផ្សេងៗ

❖ **ព័ត៌មានលម្អិតសម្រាប់អ្នកតំណាងការទាមទារតារាងការលិកផ្នែកថែទាំសុខភាព**

❺ គោត្តនាមនិងនាមអ្នកតំណាង៖ ..........................................................................ភេទ............ ថ្ងៃខែឆ្នាំកំណើត........./.........../...........

អាសយដ្ឋានផ្លូវលេខ..............សង្កាត់(ឃុំ)................................ខណ្ឌ(ស្រុក)...........................រាជធានី(ខេត្ត) ......................................

លេខទូរសព្ទ៖ [ ][ ][ ][ ][ ][ ][ ][ ][ ][ ]

លេខអត្តសញ្ញាណប័ណ្ណ/លេខលិខិតឆ្លងដែន៖ [ ][ ][ ][ ][ ][ ][ ][ ][ ][ ] ចុះថ្ងៃទី.............../.............../...............

*ខ្ញុំសូមសន្យាថារាល់ព័ត៌មានដែលបានផ្តល់ជូនខាងលើពិតជាត្រឹមត្រូវប្រាកដមែន។*

ធ្វើនៅ......................ថ្ងៃទី..............ខែ..............ឆ្នាំ២០.....

**ស្នាមមេដៃអ្នកស្នើសុំ**

❖ **ឯកសារភ្ជាប់**
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ , លិខិតឆ្លងដែនសាមីខ្លួន ឬ អ្នកស្នើសុំ
- បណ្ណសមាជិក ប.ស.ស. និង បណ្ណគណនីអេស៊ីលីដា

- **សង្គ្រោះបន្ទាន់**
  - វេជ្ជបញ្ជាសម្រាកព្យាបាល, វិក័យបត្រចំណាយវេជ្ជសាស្ត្រ
- **វិភាជន៍បូជាសព**
  - សេចក្តីចម្លងសំបុត្រមរណៈភាព
- **ប្រាក់បំណាច់មាតុភាព**
  - លិខិតចេញចូលមន្ទីរពេទ្យ
  - លិខិតបញ្ជាក់កំណើតកូន
- **ប្រាក់បំណាច់សម្រាកព្យាបាលជំងឺ**
  - លិខិតចេញចូលមន្ទីរពេទ្យ
  - លិខិតសុំអនុញ្ញាតច្បាប់ចេញដោយសហគ្រាស

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ៤៨០ ក.ប/ប្រ.ក.ប.ស.ស

# ប្រកាស

## ស្តីពី

## ការកែសម្រួលប្រការ៦ ប្រការ១១ និងប្រការ១៣ នៃប្រកាសលេខ ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ/បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញប្រកាសលេខ ១០៩ កប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៨៣ ៧៥ និងទូរសារ:(០២៣) ៨៨ ២៧ ៦៩

# សម្រេច

**ប្រការមួយ.-**

ប្រការ៦ ប្រការ១១ និងប្រការ១៣ នៃប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្ដីពីតាវកាលិកហានិភ័យការងារ ត្រូវបានកែសម្រួលដូចតទៅ៖

**ប្រការ ៦ថ្មី.-**

៦.១ ប្រាក់ឈ្នួលមធ្យម គឺជាផលចែកមធ្យមភាគនៃប្រាក់ឈ្នួលជាប់ភាគទានក្នុងរយៈពេលជាក់ស្ដែងមិនលើស ០៦(ប្រាំមួយ)ខែ មុនខែបរិច្ឆេទនៃគ្រោះថ្នាក់។ ប្រាក់ឈ្នួលជាប់ភាគទាន ត្រូវបានកំណត់ក្នុងតារាងដូចមានចែងក្នុងឧបសម្ព័ន្ធ១ នៃប្រកាសនេះ។

៦.២ ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ គឺជាផលចែក នៃប្រាក់ឈ្នួលមធ្យមដូចមានចែងក្នុងចំណុច ៦.១ នឹង៣០(សាមសិប)ថ្ងៃ។

៦.៣ ការគណនាប្រាក់ឈ្នួលមធ្យម ដែលកំណត់នៅក្នុងប្រកាសនេះមានអានុភាពចំពោះតែការគណនាតាវកាលិកសន្តិសុខសង្គម ប៉ុណ្ណោះ។

**ប្រការ ១១ថ្មី.-**

១១.១ ឧត្តរជីវី នៃជនរងគ្រោះដោយហានិភ័យការងារ ដូចមានចែងក្នុងមាត្រា៣៨នៃអនុក្រឹត្យលេខ ១៦អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្ដីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមមានសិទ្ធិទទួលបានតាវកាលិកឧត្តរជីវី។

១១.២ តាវកាលិកឧត្តរជីវី គឺជាប្រាក់ធនលាភដែលត្រូវផ្ដល់ឱ្យសិទ្ធិវន្តនៃជនរងគ្រោះតាមអត្រាដូចខាងក្រោម៖

ក. ក្នុងករណីសិទ្ធិវន្ត មានរួមទាំងប្រពន្ធ ឬប្ដី កូន និងឪពុកម្ដាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក
  - ប្រពន្ធ ឬប្ដី =៣/៥x៦៣%បឈម
  - ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក=២/៥x៦៣%បឈម
  - ធនលាភសរុបសម្រាប់ឪពុកម្ដាយ ឬមនុស្សចាស់ជរា ក្នុងបន្ទុក=៧%បឈម

ខ. ក្នុងករណីសិទ្ធិវន្តមានតែប្រពន្ធ ឬប្ដី និង/ឬកូន
  - ប្រពន្ធ ឬប្ដី =៣/៥x៧០%បឈម
  - ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក =២/៥x៧០%បឈម

គ. ក្នុងករណីសិទ្ធិវន្តមានតែឪពុកម្ដាយ ឬមនុស្សចាស់ជរា
  -ធនលាភសរុបសម្រាប់ឪពុកម្ដាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក =៣៥%បឈម

ឃ. ក្នុងករណីសិទ្ធិវន្តមានតែកូន និងឪពុកម្ដាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក
  - ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក =២៨%បឈម
  - ធនលាភសរុបសម្រាប់ឪពុកម្ដាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក =២៨%បឈម

ង. ក្នុងករណីសិទ្ធិវន្តមានតែប្រពន្ធ ឬប្ដី និងឪពុកម្ដាយ ឬមនុស្សចាស់ជរា
  - ប្រពន្ធឬប្ដី =២៨%បឈម
  - ធនលាភសរុបសម្រាប់ឪពុកម្ដាយឬមនុស្សចាស់ជរាក្នុងបន្ទុក =២៨%បឈម

ច. ក្នុងករណីសិទ្ធិវន្តមានតែប្ដី ឬប្រពន្ធឬកូន ក្នុងបន្ទុក=៥៦%បឈម

**ប្រការ ១៣ថ្មី.-**

១៣.១ ការទាមទារតាវកាលិកសម្រាប់ការថែទាំ និងការព្យាបាលអាចត្រូវបានធ្វើឡើងដោយមូលដ្ឋានសុខាភិបាលដែលព្យាបាលជនរងគ្រោះ ឬនិយោជក ឬក៏កម្មករនិយោជិតជាជនរងគ្រោះផ្ទាល់តាមទម្រង់ "**តាវកាលិកហានិភ័យការងារ**" ដូចមានចែងក្នុងឧបសម្ព័ន្ធ៤ នៃប្រកាសនេះ។

១៣.២ ការទាមទារប្រាក់បំណាច់ថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្ដោះអាសន្នត្រូវធ្វើឡើងដោយជនរងគ្រោះ ឬតំណាងតាមទម្រង់ "**តាវកាលិកហានិភ័យការងារ**" ដូចមានចែងក្នុងឧបសម្ព័ន្ធ៤ នៃប្រកាសនេះ។ បែបបទនៃការទាមទារនេះត្រូវមានភ្ជាប់ជាមួយនូវវេជ្ជបញ្ជា និងលិខិតបញ្ជាក់ពីគ្រូពេទ្យព្យាបាលផ្លូវការ។

១៣.៣ ការទាមទារតាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ត្រូវធ្វើឡើងដោយជនរងគ្រោះតាមទម្រង់ "**តាវកាលិកហានិភ័យការងារ**" ដូចមានចែងក្នុងឧបសម្ព័ន្ធ៤នៃប្រកាសនេះ។ ក្នុងករណីដែលជនរងគ្រោះមិនអាចមានសមត្ថភាពក្នុងការទាមទារតាវកាលិកបាន ដោយសារស្ថានភាពនៃការបាត់បង់សមត្ថភាពការងារធ្ងន់ធ្ងរ ការទាមទារនេះអាចត្រូវធ្វើឡើងដោយអ្នកតំណាងជនរងគ្រោះ។ អ្នកតំណាងជនរងគ្រោះ អាចជាប្ដី ប្រពន្ធ កូន ឬជនដែលមានភារៈថែរក្សាដោយផ្ទាល់ចំពោះជនរងគ្រោះ។

១៣.៤ ការទាមទារតាវកាលិកឧត្តរជីវី និងសោហ៊ុយបូជាសព ត្រូវធ្វើឡើងដោយសិទ្ធិវន្តនៃជនរងគ្រោះ ឬ អ្នកតំណាងតាមទម្រង់ "**តាវកាលិកហានិភ័យការងារ**" ដូចមានចែងក្នុងឧបសម្ព័ន្ធ៤ នៃប្រកាសនេះ។

១៣.៥ សិទ្ធិនៃការទាមទារបំណាច់ប្រចាំថ្ងៃសម្រាប់ហានិភ័យការងារ និងប្រាក់វិភាជន៍បូជាសព ត្រូវអស់សុពលភាពត្រឹមរយៈពេល០១(មួយ)ឆ្នាំ។ ចំពោះសិទ្ធិក្នុងការទាមទារប្រាក់ធនលាភត្រូវអស់សុពលភាពត្រឹមរយៈពេល០៥(ប្រាំ)ឆ្នាំ។

១៣.៦ ការបើកប្រាក់ធនលាភ ត្រូវធ្វើជាប្រចាំខែ។

**ប្រការពីរ.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ក្រុមប្រឹក្សាភិបាល នៃប.ស.ស
  "ដើម្បីជូនជ្រាប"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ១ នៃប្រកាសលេខ...២៨០....ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី..១៨..ខែ..ធ្នូ..ឆ្នាំ២០១៨ ស្តីពីការកែសម្រួលប្រការ៦ ប្រការ១១ និងប្រការ១៣ នៃប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការកាលិកហានិភ័យការងារ

# តារាងប្រាក់ឈ្នួលជាប់ភាគទាន

| ថ្នាក់ | ចំនួនប្រាក់ឈ្នួលសរុប (រៀល) | ប្រាក់ឈ្នួលជាប់ភាគទាន (រៀល) |
|---|---|---|
| ១ | ២០០ ០០០ ចុះ | ២០០ ០០០ |
| ២ | ២០០ ០០១ - ២៥០ ០០០ | ២២៥ ០០០ |
| ៣ | ២៥០ ០០១ - ៣០០ ០០០ | ២៧៥ ០០០ |
| ៤ | ៣០០ ០០១ - ៣៥០ ០០០ | ៣២៥ ០០០ |
| ៥ | ៣៥០ ០០១ - ៤០០ ០០០ | ៣៧៥ ០០០ |
| ៦ | ៤០០ ០០១ - ៤៥០ ០០០ | ៤២៥ ០០០ |
| ៧ | ៤៥០ ០០១ - ៥០០ ០០០ | ៤៧៥ ០០០ |
| ៨ | ៥០០ ០០១ - ៥៥០ ០០០ | ៥២៥ ០០០ |
| ៩ | ៥៥០ ០០១ - ៦០០ ០០០ | ៥៧៥ ០០០ |
| ១០ | ៦០០ ០០១ -៦៥០ ០០០ | ៦២៥ ០០០ |
| ១១ | ៦៥០ ០០១ - ៧០០ ០០០ | ៦៧៥ ០០០ |
| ១២ | ៧០០ ០០១ - ៧៥០ ០០០ | ៧២៥ ០០០ |
| ១៣ | ៧៥០ ០០១ - ៨០០ ០០០ | ៧៧៥ ០០០ |
| ១៤ | ៨០០ ០០១ - ៨៥០ ០០០ | ៨២៥ ០០០ |
| ១៥ | ៨៥០ ០០១ - ៩០០ ០០០ | ៨៧៥ ០០០ |
| ១៦ | ៩០០ ០០១ - ៩៥០ ០០០ | ៩២៥ ០០០ |
| ១៧ | ៩៥០ ០០១ - ១ ០០០ ០០០ | ៩៧៥ ០០០ |
| ១៨ | ១ ០០០ ០០១ - ១ ០៥០ ០០០ | ១ ០២៥ ០០០ |
| ១៩ | ១ ០៥០ ០០១ - ១ ១០០ ០០០ | ១ ០៧៥ ០០០ |
| ២០ | ១ ១០០ ០០១ - ១ ១៥០ ០០០ | ១ ១២៥ ០០០ |
| ២១ | ១ ១៥០ ០០១ - ១ ២០០ ០០០ | ១ ១៧៥ ០០០ |
| ២២ | ១ ២០០ ០០១ ឡើង | ១ ២០០ ០០០ |

*ឧបសម្ព័ន្ធ៤ នៃប្រកាសលេខ...៤៨០.....ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី..១៨..ខែ..តុលា..ឆ្នាំ២០១៨ ស្តីពីការកែសម្រួលប្រការ៦ ប្រការ១១ និងប្រការ១៣ នៃប្រកាសលេខ១០៩ ក.ប/ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីគាំពារការលិកហានិភ័យការងារ*

**សម្រាប់មន្ត្រី ប.ស.ស**
លេខតារាកាលិក ☐☐☐☐☐/☐☐
ហត្ថលេខា ......../......../........

# តារាងកាលិកហានិភ័យការងារ

① នាមករណ៍សហគ្រាស៖........................................ លេខអត្តសញ្ញាណសហគ្រាស៖ ☐☐☐☐☐☐☐☐

លេខទូរស័ព្ទ៖ ☐☐☐☐☐☐☐☐☐☐ ☐☐☐☐☐☐☐☐☐☐ អ៊ីម៉ែលE-Mail:........................................

② គោត្តនាមនិងនាមកម្មករនិយោជិត៖........................................ ភេទ៖...............

លេខអត្ត.កម្មករនិយោជិត៖ ☐☐☐☐☐☐☐☐☐☐☐☐☐☐☐ លេខទូរស័ព្ទ៖ ☐☐☐☐☐☐☐☐☐☐

③ ប្រភេទគ្រោះថ្នាក់: ☐ ធ្វើដំណើរ ☐ កន្លែងធ្វើការ ☐ ជម្ងឺវិជ្ជាជីវៈ គ្រោះថ្នាក់ថ្ងៃខែឆ្នាំ:........./........./............ ម៉ោងគ្រោះថ្នាក់: ☐☐ ☐☐

-មូលហេតុគ្រោះថ្នាក់........................................ បណ្តាលឲ្យរបួស........................................

④ ឈ្មោះមន្ទីរពេទ្យ/មន្ទីរពហុព្យាបាល៖ ........................................

-ចំនួនថ្ងៃសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ/មន្ទីរពហុព្យាបាល៖ ..............ថ្ងៃ ចាប់ពីថ្ងៃខែឆ្នាំ......... /........./........... ដល់ថ្ងៃខែឆ្នាំ......... /........./...........

-ចំនួនថ្ងៃសម្រាកព្យាបាលបន្តនៅផ្ទះ៖ ..............ថ្ងៃ ចាប់ពីថ្ងៃខែឆ្នាំ......... /........./........... ដល់ថ្ងៃខែឆ្នាំ......... /........./...........

⑤ **ការទាមទារតាវកាលិកហានិភ័យការងារ**

☐ **តាវកាលិកព្យាបាល** ☐ **តាវកាលិកថែទាំ** ☐ **តាវកាលិកបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន** ☐ **តាវកាលិកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍**

☐ **តាវកាលិកអ្នកចាំថែរក្សា** ☐ **ប្រាក់វិភាជន៍បូជាសព** ☐ **តាវកាលិកឧត្តរជីវី**

* **ព័ត៌មានលំអិតសម្រាប់សាមីខ្លួនឬអ្នកតំណាងទាមទារតាវកាលិកផ្នែកហានិភ័យការងារ**

⑥ គោត្តនាមនិងនាមសាមីខ្លួនឬអ្នកតំណាង៖ ........................................ ភេទ៖ ............. ថ្ងៃខែឆ្នាំកំណើត............ /.........../...............

អាសយដ្ឋានផ្ទះលេខ..............ផ្លូវលេខ.............. ភូមិ....................សង្កាត់(ឃុំ)...........................ខណ្ឌ(ស្រុក)........................... រាជធានី(ខេត្ត) ........................

លេខទូរស័ព្ទ៖ ☐☐☐☐☐☐☐☐☐☐

លេខអត្តសញ្ញាណប័ណ្ណ/លេខលិខិតឆ្លងដែន៖ ☐☐☐☐☐☐☐☐☐☐ ចុះថ្ងៃទី............ /.........../...............

*ខ្ញុំសូមសន្យាថារាល់ព័ត៌មានដែលបានផ្តល់ជូនខាងលើពិតជាត្រឹមត្រូវប្រាកដមែន។*

ថ្ងៃ...............................ខែ....................ឆ្នាំ.......................ព.ស.២៥......

..................... ថ្ងៃទី........... ខែ.............. ឆ្នាំ២០........

**ស្នាមមេដៃស្តាំអ្នកស្នើសុំ**

* **ឯកសារភ្ជាប់៖**
-ឯកសារវេជ្ជសាស្ត្រ-អមវេជ្ជសាស្ត្រ
-វិក្កយបត្រចំណាយព្យាបាល
-លិខិតចេញចូលមន្ទីរពេទ្យ/វេជ្ជបញ្ជា
-លិខិតសុំអនុញ្ញាតិច្បាប់
-សេចក្តីចម្លងសំបុត្រកំណើត
-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍
-សេចក្តីចម្លងសំបុត្រមរណភាព
-អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនអ្នកស្នើសុំឬជនរងគ្រោះ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌបែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងធានាចីរភាព ប្រសិទ្ធភាព ស្ថិរភាព និងនិរន្តរភាពនៃការគ្រប់គ្រង និងអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈ ដោយកំណត់អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈ។

មាត្រា២ .-

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះ របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈ ដូចមានចែងក្នុងចំណុច ១ នៃមាត្រា៣ នៃព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម។

## ជំពូកទី ២

## ការកំណត់អត្រាភាគទានផ្នែកហានិភ័យការងារ

មាត្រា៣ .-

ភាគទាននៃរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈ គឺជាបន្ទុករបស់រដ្ឋ។

អត្រាភាគទាន ផ្នែកហានិភ័យការងារត្រូវកំណត់ស្មើ ០,៦% (សូន្យក្បៀសពីរ) ភាគរយ នៃប្រាក់បៀវត្សមូលដ្ឋានប្រចាំខែរបស់បុគ្គលនៃវិស័យសាធារណៈ។

## ជំពូកទី ៣

## ការចុះបញ្ជី និងការទូទាត់ថ្លៃសេវាផ្នែកហានិភ័យការងារ

## ផ្នែកទី ១

## ការចុះបញ្ជី និងការចេញលេខអត្តសញ្ញាណសមាជិក

មាត្រា៤ .-

បុគ្គលនៃវិស័យសាធារណៈ ដែលមានឈ្មោះស្រាប់ក្នុងប្រព័ន្ធទិន្នន័យនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពរបស់បេឡាជាតិសន្តិសុខសង្គម(ប.ស.ស.) លើកលែងតែមន្ត្រីនគរបាលជាតិ មន្ត្រីពន្ធនាគារ អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ត្រូវបាន ប.ស.ស. ចុះបញ្ជីដោយស្វ័យប្រវត្តិចូលក្នុងប្រព័ន្ធទិន្នន័យនៃរបបសន្តិសុខសង្គមផ្នែកហានិភ័យការងាររបស់ ប.ស.ស. ដោយរក្សានូវលេខអត្តសញ្ញាណសមាជិក និងប័ណ្ណ ប.ស.ស. ដដែល។

ចំពោះបុគ្គលនៃវិស័យសាធារណៈដូចមានចែងក្នុងមាត្រា២ នៃអនុក្រឹត្យនេះដែលទើបចូលបម្រើការងារថ្មី ប.ស.ស. ត្រូវចុះឈ្មោះចូលក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យនៃរបបសន្តិសុខសង្គមទាំងផ្នែកថែទាំសុខភាព និងផ្នែកហានិភ័យការងារ។ ប.ស.ស. ត្រូវចេញលេខអត្តសញ្ញាណសមាជិក ប.ស.ស. សម្រាប់បុគ្គលនៃវិស័យសាធារណៈ ដោយអនុលោមតាមលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។ ដើម្បីអនុវត្តការចេញលេខអត្តសញ្ញាណសមាជិកនេះ ក្រសួង-ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធមានភារកិច្ច÷

- ក្រសួងមុខងារសាធារណៈត្រូវផ្តល់ទិន្នន័យបុគ្គលនៃវិស័យសាធារណៈ និងមន្ត្រីជាប់កិច្ចសន្យា និងទំហំថវិកាភាគទានតាមក្រសួង-ស្ថាប័ន ឬអង្គភាព មក ប.ស.ស. ជារៀងរាល់ខែ
- ក្រសួង-ស្ថាប័ន ឬអង្គភាព ដែលគ្រប់គ្រងលើបុគ្គលនៃវិស័យសាធារណៈត្រូវផ្តល់ទិន្នន័យបុគ្គលនៃវិស័យសាធារណៈ ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងមុខងារសាធារណៈមក ប.ស.ស. ជារៀងរាល់ខែ។

## ផ្នែកទី ២
## ការទូទាត់ថ្លៃសេវាផ្នែកហានិភ័យការងារ

**មាត្រា៥ .-**

ការផ្តល់សេវាព្យាបាល និងថៃទាំវេជ្ជសាស្ត្រផ្នែកហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈ ត្រូវបានទូទាត់សងតាមយន្តការថ្លៃតាមសេវា។

ការព្យាបាលរបស់បុគ្គលនៃវិស័យសាធារណៈ ដែលរងគ្រោះដោយហានិភ័យការងារត្រូវអនុវត្តដោយមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.។

ក្នុងករណីដែលសេវានេះធ្វើនៅមូលដ្ឋានសុខាភិបាលដែលមិនបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. រួមបញ្ចូលទាំងករណីសង្គ្រោះបន្ទាន់ សាមីជនរងគ្រោះដោយហានិភ័យការងារអាចទាមទារការទូទាត់ថ្លៃព្យាបាល និងថៃទាំវេជ្ជសាស្ត្របាន ទៅតាមតម្លៃសមស្របជាក់ស្តែងរបស់មូលដ្ឋានសុខាភិបាល ដែលបានព្រមព្រៀងជាមួយ ប.ស.ស.។

## ជំពូកទី ៤
## ការគ្រោងថវិកាភាគទាន និងនីតិវិធីបើកផ្តល់ថវិកាផ្នែកហានិភ័យការងារជូន ប.ស.ស.

## ផ្នែកទី ១
## ការគ្រោងថវិកាភាគទានហានិភ័យការងារ

**មាត្រា៦ .-**

ឥណទានថវិកាភាគទានផ្នែកហានិភ័យការងារដែលជាបន្ទុករបស់រដ្ឋ ត្រូវគ្រោងក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងសុខាភិបាល។

**មាត្រា៧ .-**

នៅពេលរៀបចំថវិកាប្រចាំឆ្នាំ ក្រសួងសុខាភិបាលមានភារកិច្ចគ្រោងឥណទានថវិកាភាគទានផ្នែកហានិភ័យ-ការងារដែលទទួលបន្ទុកដោយរដ្ឋ ដោយផ្អែកលើមូលដ្ឋានផែនការក្របខណ្ឌមន្ត្រីសាធារណៈប្រចាំឆ្នាំរបស់ក្រសួងមុខងារ-សាធារណៈ ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ។

## ផ្នែកទី ២
## នីតិវិធីបើកផ្តល់ថវិកាហានិភ័យការងារ

**មាត្រា៨ .-**

ក្រសួងសុខាភិបាល ដោយផ្អែកតាមការស្នើសុំរបស់ ប.ស.ស. ត្រូវបោះអាណត្តិបើកប្រាក់ប្រចាំត្រីមាស ដើម្បីបង្វែរសាច់ប្រាក់ភាគទានហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈ ដែលជាបន្ទុករបស់រដ្ឋមកចូលក្នុងគណនីប្រាក់បញ្ញើរបស់ ប.ស.ស. នៅរតនាគារជាតិ។

**មាត្រា៩ .-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចចេញប្រកាសស្តីពីនីតិវិធីអនុវត្តថវិកាលម្អិតបន្ថែម តាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តថវិកាដែលជាភាគទានហានិភ័យការងារសម្រាប់បុគ្គលនៃវិស័យសាធារណៈ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា១០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ តទៅ។

ថ្ងៃពុធ ៥ កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**រដ្ឋមន្ត្រី**
**ក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ១. នៃប្រកាសលេខៈ ១៦៨/២២ ក.ប/ប្រ.ក.ប.ស.ស. ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២២ ស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងការបង់ភាគទាន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងរបបសន្តិសុខសង្គម

**ទម្រង់ ១.0១**

# បញ្ជិកាសហគ្រាស គ្រឹះស្ថាន

**សម្រាប់មន្ត្រី ប.ស.ស.**

**លេខអត្តសញ្ញាណសហគ្រាស គ្រឹះស្ថានៈ** ☐☐☐☐☐☐☐☐

**ហត្ថលេខាៈ**............................ / /

**១.** ឈ្មោះសហគ្រាស គ្រឹះស្ថានៈ............................................................

ឈ្មោះជាអក្សរឡាតាំងៈ............................................................

**២.** អាសយដ្ឋានទីស្នាក់ការកណ្តាលៈអគារ/ផ្ទះលេខ....................ផ្លូវ....................ភូមិ....................ឃុំ/សង្កាត់....................

ស្រុក/ខណ្ឌ/ក្រុង..............................រាជធានី/ខេត្ត..............................លេខទូរស័ព្ទៈ ☐☐☐☐☐☐☐☐☐☐

លេខទូរសារៈ ☐☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិកៈ............................................................

**៣.** អាសយដ្ឋាននៃកន្លែងធ្វើការងារៈអគារ/ផ្ទះលេខ....................ផ្លូវ....................ភូមិ....................ឃុំ/សង្កាត់....................

ស្រុក/ខណ្ឌ/ក្រុង..............................រាជធានី/ខេត្ត..............................លេខទូរស័ព្ទៈ ☐☐☐☐☐☐☐☐☐☐

លេខទូរសារៈ ☐☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិកៈ............................................................

(ប្រសិនបើអាសយដ្ឋានកន្លែងធ្វើការដូចគ្នាជាមួយនឹងអាសយដ្ឋានទីស្នាក់ការកណ្តាល ចំណុចលេខ ៣ នេះពុំចាំបាច់ត្រូវបំពេញទេ)

**៤.** លេខបញ្ជីពាណិជ្ជកម្មៈ ☐☐☐☐☐☐☐☐☐☐☐☐ ប្រភេទសហគ្រាស គ្រឹះស្ថានៈ ☐☐☐☐ **(សម្រាប់មន្ត្រី ប.ស.ស.)**

កាលបរិច្ឆេទបើកសហគ្រាស គ្រឹះស្ថានៈ ........../........../.......... ចំនួនកម្មករនិយោជិតចុះបញ្ជីដំបូងៈ....................នាក់/ស្រី..............នាក់

**៥.** ឈ្មោះនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានៈ..............................ភេទៈ..............សញ្ជាតិៈ....................

ឈ្មោះជាអក្សរឡាតាំងៈ............................................................

អត្តសញ្ញាណប័ណ្ណលេខ ឬលិខិតឆ្លងដែនលេខៈ............................................................

អាសយដ្ឋានអចិន្ត្រៃយ៍ៈអគារ/ផ្ទះលេខ....................ផ្លូវ....................ភូមិ....................ឃុំ/សង្កាត់....................

ស្រុក/ខណ្ឌ/ក្រុង..............................រាជធានី/ខេត្ត..............................លេខទូរស័ព្ទៈ ☐☐☐☐☐☐☐☐☐☐

លេខទូរសារៈ ☐☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិកៈ............................................................

**៦.** ឈ្មោះអ្នកគ្រប់គ្រង ឬអ្នកតំណាងនិយោជកៈ..............................ភេទៈ..............សញ្ជាតិៈ....................

ឈ្មោះជាអក្សរឡាតាំងៈ............................................................

អត្តសញ្ញាណប័ណ្ណលេខ ឬលិខិតឆ្លងដែនលេខៈ............................................................

អាសយដ្ឋានអចិន្ត្រៃយ៍ៈអគារ/ផ្ទះលេខ....................ផ្លូវ....................ភូមិ....................ឃុំ/សង្កាត់....................

ស្រុក/ខណ្ឌ/ក្រុង..............................រាជធានី/ខេត្ត..............................លេខទូរស័ព្ទៈ ☐☐☐☐☐☐☐☐☐☐

លេខទូរសារៈ ☐☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិកៈ............................................................

ខ្ញុំសូមសន្យាថា រាល់ព័ត៌មានដែលផ្តល់ជូនខាងលើ ពិតជាត្រឹមត្រូវប្រាកដមែន។

....................ថ្ងៃទី..........ខែ..............ឆ្នាំ..............

**ហត្ថលេខា និងត្រានិយោជក**

**ឯកសារថតចម្លងភ្ជាប់មកជាមួយៈ**

- បញ្ជីពាណិជ្ជកម្ម
- ប័ណ្ណប៉ាតង់
- លិខិតឧបករណ៍គតិយុត្តសមមូល
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់និយោជក និងអ្នកតំណាងនិយោជក
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅរបស់និយោជក

ឧបសម្ព័ន្ធ២. នៃប្រកាសលេខៈ១៦៨/២២ ក.ប/ប្រ.ក.ប.ស.ស. ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២២ ស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងការបង់ភាគទាន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងបេឡាជាតិសន្តិសុខសង្គម

**ទម្រង់ ១.០២**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សលាកប័ត្រព័ត៌មានសមាជិក ប.ស.ស.

លេខ៖ ..............................

**លេខអត្តសញ្ញាណសមាជិក ប.ស.ស.**

☐☐☐☐☐☐☐ - ☐☐☐☐☐☐☐ - ☐

## ក- ព័ត៌មានផ្ទាល់ខ្លួន

១- គោត្តនាម..................... នាម........................................ ជាអក្សរឡាតាំង..............................................................
ភេទ......... សញ្ជាតិ.................... ថ្ងៃខែឆ្នាំកំណើត ....../........../........... អត្តសញ្ញាណប័ណ្ណលេខ...................................

២- ទីកន្លែងកំណើត ផ្ទះលេខ.............. ផ្លូវ.................. ភូមិ/ក្រុម............................ ឃុំ/សង្កាត់......................................
ស្រុក/ខណ្ឌ/ក្រុង........................................... ខេត្ត/រាជធានី..............................................................................................

៣- អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ............... ផ្លូវ.................. ភូមិ/ក្រុម.......................... ឃុំ/សង្កាត់.................................
ស្រុក/ខណ្ឌ/ក្រុង............................... ខេត្ត/រាជធានី..................................... លេខទូរស័ព្ទៈ........................................

## ខ- ព័ត៌មានការងារ

៤- សហគ្រាស គ្រឹះស្ថាន.............................................................. លេខអត្តសញ្ញាណស.ហ ☐☐☐☐☐☐☐☐

៥- មុខងារ.............................................. ប្រាក់ឈ្នួល......................... កាលបរិច្ឆេទចូលធ្វើការ......../........./..........

## គ- ព័ត៌មានគ្រួសារ

៦- ☐ នៅលីវ ☐ រៀបអាពាហ៍ពិពាហ៍ ☐ មេម៉ាយ/ពោះម៉ាយ

៧- គោត្តនាម-នាម.................................................. សញ្ជាតិ....................... ថ្ងៃខែឆ្នាំកំណើត......../........../...........
មុខរបរសព្វថ្ងៃ..........................................................................................................................................................

៨- អំពីកូន...........នាក់
១. គោត្តនាម-នាម ......................................... ភេទ....... កើតនៅថ្ងៃទី.......ខែ ....... ឆ្នាំ.......... មុខរបរ ........................
២. គោត្តនាម-នាម ......................................... ភេទ....... កើតនៅថ្ងៃទី.......ខែ ....... ឆ្នាំ.......... មុខរបរ ........................
៣. គោត្តនាម-នាម ......................................... ភេទ....... កើតនៅថ្ងៃទី.......ខែ ....... ឆ្នាំ.......... មុខរបរ ........................
៤. គោត្តនាម-នាម ......................................... ភេទ....... កើតនៅថ្ងៃទី.......ខែ ....... ឆ្នាំ.......... មុខរបរ ........................

ខ្ញុំបាទ/នាងខ្ញុំ សូមធានាទទួលខុសត្រូវចំពោះមុខច្បាប់ថា ព័ត៌មានបំពេញខាងលើនេះពិតជាត្រឹមត្រូវប្រាកដមែន ។

ធ្វើនៅ.............ថ្ងៃទី.........ខែ.............ឆ្នាំ២០...

**ស្នាមមេដៃស្តាំសាមីខ្លួន**

ធ្វើនៅ............ថ្ងៃទី..........ខែ...........ឆ្នាំ២០...

**ហត្ថលេខា និងឈ្មោះមន្ត្រីពិនិត្យ**

**ឯកសារថតចម្លងភ្ជាប់ជាមួយៈ**
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- លិខិតឆ្លងដែន
- លិខិតបញ្ជាក់ការងារពីនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន


№21-22
INTERNET ROOM